# គណិតវិទ្យាសិស្សពូកែ

## មធ្យមសិក្សាទុតិយភូមិ




រៀបរៀងដោយ នូ ច័ន្ទណារិទ្ធិ

រក្សាសិទ្ធិ

like us on facebook
បណ្ណាគារបាក់ទូក ॥

**០១** គេអោយ $4\le k\le n$ ។

ស្រាយបញ្ជាក់ថា $C_n^k+4.C_n^{k-1}+6.C_n^{k-2}+4.C_n^{k-3}+C_n^{k-4}=C_{n+4}^k$ ។

**ដំណោះស្រាយ**

គេមាន $C_n^k+4.C_n^{k-1}+6.C_n^{k-2}+4.C_n^{k-3}+C_n^{k-4}=\left(C_n^k+C_n^{k-1}\right)+3\left(C_n^{k-1}+C_n^{k-2}\right)$

$+3\left(C_n^{k-2}+C_n^{k-3}\right)+\left(C_n^{k-3}+C_n^{k-4}\right)$

$=C_{n+1}^k+3.C_{n+1}^{k-1}+3.C_{n+1}^{k-2}+C_{n+1}^{k-3}$

$=\left(C_{n+1}^k+C_{n+1}^{k-1}\right)+2\left(C_{n+1}^{k-1}+C_{n+1}^{k-2}\right)+\left(C_{n+1}^{k-2}+C_{n+1}^{k-3}\right)$

$=C_{n+2}^k+2.C_{n+2}^{k-1}+C_{n+1}^{k-3}$

$=\left(C_{n+2}^k+C_{n+2}^{k-1}\right)+\left(C_{n+2}^{k-1}+C_{n+2}^{k-3}\right)$

$=C_{n+3}^k+C_{n+3}^{k-1}=C_{n+4}^k$ ពិត

**០២** ស្រាយបញ្ជាក់ថា $\dfrac{a}{\sqrt{a^2+bc}}+\dfrac{b}{\sqrt{b^2+ac}}+\dfrac{c}{\sqrt{c^2+ab}}\ge 1$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$ ។

ដំណោះស្រាយ

តាង $a=x^3,b=y^3$ និង $c=z^3$

យក $I=\dfrac{a}{\sqrt{a^2+bc}}+\dfrac{b}{\sqrt{b^2+ac}}+\dfrac{c}{\sqrt{c^2+ab}}$

$$I=\frac{x^3}{\sqrt{x^6+8y^3z^3}}+\frac{y^3}{\sqrt{y^6+8x^3z^3}}+\frac{z^3}{\sqrt{z^6+8x^3y^3}}$$

$$I=\frac{1}{\sqrt{1+\left(\frac{2yz}{x^2}\right)^3}}+\frac{1}{\sqrt{1+\left(\frac{2xz}{y^2}\right)^3}}+\frac{1}{\sqrt{1+\left(\frac{x^3y^3}{z^2}\right)^3}}$$

ដោយ $1+\left(\dfrac{2yz}{x^2}\right)^3=\left(1+\dfrac{2yz}{x^2}\right)\left(1-\dfrac{2yz}{x^2}+\dfrac{4y^2z^2}{x^4}\right)$

តាមវិសមភាព AM-GM យើងបាន

$1+\left(\dfrac{2yz}{x^2}\right)^3\le\dfrac{x^4+y^2z^2}{x^4}$ នោះ $\dfrac{1}{\sqrt{1+\left(\frac{2yz}{x^2}\right)^3}}\ge\dfrac{x^4}{x^4+2y^2z^2}$

នាំអោយ $I \geq \frac{x^4}{x^4+y^4+z^4}+\frac{y^4}{x^4+y^4+z^4}+\frac{z^4}{x^4+y^4+z^4}$

នាំអោយ $I \geq 1$ ពិត

**០៣** ឧបមាថា $a,b,c \in Z$ ហើយតាង $d=\gcd(a;b)$ ។ ស្រាយបញ្ជាក់ថា

(1) សមីការ $ax+by=c$ មានចម្លើយកាលណា $d \mid c$ ។

(2) បើ $x_0, y_0$ ជាចម្លើយពិសេសនៃសមីការនេះ នោះចម្លើយទាំងអស់មានទម្រង់

$x=x_0+\frac{b}{d}t$ , $y=y_0-\frac{b}{d}t$ ដែល $t \in Z$ ។

ដំណោះស្រាយ

(1) បើ $d=\gcd(a;b)$ នោះ $d \mid a$ និង $d \mid b$

$\Rightarrow a=dr$ និង $b=ds$ $,r,s$ ជាចំនួនគត់

បើ $x=x_0$ និង $y=y_0$ ជាចម្លើយនៃសមីការ $ax+by=c$ នោះ $ax_0+by_0=c$

$\Rightarrow c=ax_0+by_0=drx_0+dsy_0=d(rx_0+sy_0)$

នាំអោយ $d \mid c$

ដូចនេះ សមីការ $ax+by=c$ មានចម្លើយកាលណា $d \mid c$

(2) បើ $x_0, y_0$ ជាចម្លើយពិសេសនៃសមីការនេះ នោះចម្លើយទាំងអស់មានទម្រង់

$x=x_0+\frac{b}{d}t$ , $y=y_0-\frac{b}{d}t$ ដែល $t \in Z$

$x_0, y_0$ ជាចម្លើយនៃសមីការ $ax+by=c$ នោះ $ax_0+by_0=c$

បើ $x', y'$ ជាចម្លើយផ្សេងទៀត នោះ $ax'+by'=c$

នាំអោយ $a(x_0-x')=b(y'-y_0)$ (1)

ដោយ $d=\gcd(a,b)$ នោះមានចំនួនគត់ $r,s$ បឋមរវាងគ្នាដែល $a=dr$ និង $b=ds$

$\Rightarrow dr(x_0-x')=ds(y'-y_0)$

$\Rightarrow r(x_0-x')=s(y'-y_0)$

$\Rightarrow r \mid s(y'-y_0)$ ដែល $\gcd(r,s)=1$ (2)

តាម Euclid’s Lemma បើ $a \mid bc$ ហើយ $\gcd(a,b)=1$ នោះ $a \mid c$

នោះតាម (2) គេបាន $r \mid (y_0-y')$

នាំអោយ $y_0-y'=rt$ ចំពោះ $t \in Z$

នោះ $y'=y_0-rt$

ជំនួសចូល (1) យើងបាន $a(x_o-x')=b(-rt)$

$dr(x_0-x')=ds(-rt)$ នោះ $x'=x_0+st$

ដូចនេះ $x'=x_0+\left(\frac{b}{d}\right)t$ និង $y'=y_0-\left(\frac{a}{d}\right)t$ ដែល $t\in Z$

ផ្ទៀងផ្ទាត់បើ $x=x_0+\left(\frac{b}{d}\right)t$ និង $y=y_0-\left(\frac{a}{d}\right)t$

គេបាន $ax+by=a\left(x_0+\frac{b}{d}t\right)+b\left(y_0-\frac{a}{d}t\right)=ax_0+by_0=c$

**០៤** តាង $S_n$ ជាផលបូក $n$ តួដំបូងនៃស្វីត $\{a_n\}$ ផ្ទៀងផ្ទាត់

$S_n+a_n=\frac{n-1}{n(n+1)}$ , $n=1,2,...$ ។ ចូររកតួទី $n$ ។

ដំណោះស្រាយ

គេមាន $a_{n+1}=S_{n+1}-S_n$

$$a_{n+1}=\frac{n}{(n+1)(n+2)}-a_{n+1}-\frac{n-1}{n(n+1)}+a_n$$

$$2a_{n+1}=\frac{n+2-2}{(n+1)(n+2)}-\frac{1}{n+1}+\frac{1}{n(n+1)}+a_n$$

$$=\frac{-2}{(n+1)(n+2)}+a_n+\frac{1}{n(n+1)}$$

គេបាន $a_{n+1}+\frac{1}{(n+1)(n+2)}=\frac{1}{2}\left(a_n+\frac{1}{n(n+1)}\right)$

យក $b_n=a_n+\frac{1}{n(n+1)}$ នោះ $b_{n+1}=a_{n+1}+\frac{1}{(n+1)(n+2)}$

នាំអោយ $b_{n+1}=\frac{1}{2}b_n$ ទំនាក់ទំនងនេះបញ្ជាក់ថា $(b_n)$ ជាស្វីតធរណីមាត្រដែលមានរេសុង $q=\frac{1}{2}$ និង

$b_1=a_1+\frac{1}{1.2}=0+\frac{1}{2}$

គេបាន $b_n=b_1.q^{n-1}=\frac{1}{2}\left(\frac{1}{2}\right)^{n-1}=\left(\frac{1}{2}\right)^n$

ដូចនេះ $a_n=\frac{1}{2^n}-\frac{1}{n(n+1)}$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

**០៥** $P$ ជាចំនុចមួយចល័តនៅលើប៉ារ៉ាបូល $y^2=2x$ ។ ចំណុច $B$ និង $C$ នៅលើអ័ក្ស $y$ ហើយរង្វង់ $(x-1)^2+y^2=1$ ប៉ះខាងក្នុងទៅនឹងត្រីកោណ $PBC$ ។ រកតម្លៃអប្បបរមាក្រឡាផ្ទៃ នៃត្រីកោណ $\Delta PBC$ ។




ដំណោះស្រាយ

តាង $P(x_0,y_0)$ , $B(0,b)$ និង $C(0,c)$ ដែល $b>c$

សមីការបន្ទាត់ $(PB):\dfrac{y-b}{y_0-b}=\dfrac{x-0}{x_0-0}$

$$(PB): y-b=\frac{y_0-b}{x_0}.x$$

នោះ $(y_0-b)x-x_0y+x_0b=0$

ចម្ងាយពីផ្ចិតនៃរង្វង់ទៅបន្ទាត់ $PB$ គឺ $d=1$

តែ $d=\dfrac{|y_0-b+x_0b|}{\sqrt{(y_0-b)^2+x_0^2}}$

នាំអោយ $\dfrac{|y_0-b+x_0b|}{\sqrt{(y_0-b)^2+x_0^2}}=1$

$\Rightarrow\ (y_0-b)^2+x_0^2=(y_0-b)^2+2(y_0-b)x_0b+x_0^2b^2$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

គេឃើញថា $x_0>2$ ហើយសមីការក្លាយជា $(x_0-2)b^2+2y_0b-x_0=0$

ដូចគ្នាដែរ $(x_0-2)c^2+2y_0c-x_0=0$

នាំអោយ $b+c=\frac{-2y_0}{x_0-2}$ និង $bc=\frac{-x_0}{x_0-2}$

យើងបាន $(b-c)^2=\frac{4x_0^2+4y_0^2-8x_0}{(x_0-2)^2}$

ដោយចំណុច $P(x_0,y_0)$ នៅលើប៉ារ៉ាបូល $y^2=2x$ នោះ $(b-c)^2=\frac{4x_0^2}{(x_0-2)^2}$

ឬ $b-c=\frac{2x_0}{x_0-2}$

ក្រឡាផ្ទៃត្រីកោណ $PBC$ គឺ $S_{\Delta PBC}=\frac{1}{2}(b-c)\times x_0$

$$=\frac{x_0}{x_0-2}\times x_0$$

$$=(x_0-2)+\frac{4}{x_0-2}+4$$

$S_{\Delta PBC}\geq 4+4=8$

សមភាពកើតមានកាលណា $x_0-2=2$ នោះ $x_0=4$ , $y_0=\pm 2\sqrt{2}$

ដូចនេះ ក្រឡាផ្ទៃអប្បបរមាគឺ $S_{\Delta PBC=8}$

**០៦** តាង $f(x)=\frac{x}{\sqrt{1+x^2}}$ និង $f^{(n)}(x)=\underbrace{f\left[f\left[f....\left[f(x)\right]\right]\right]}_{n}$ ។

ចូររក $f^{(99)}(1)$ ។

ដំណោះស្រាយ

យើងមាន $f^{(1)}(x)=f(x)=\frac{x}{\sqrt{1+x^2}}$

$$f^{(2)}(x)=f\left[f^{(1)}(x)\right]=\frac{\frac{x}{\sqrt{1+x^2}}}{\sqrt{1+\left(\frac{x}{\sqrt{1+x^2}}\right)^2}}=\frac{x}{\sqrt{1+2x^2}}$$

ស្រាយតាមលំនាំនេះបន្តទៀត យើងបាន $f^{(99)}(x)=\frac{x}{\sqrt{1+99x^2}}$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ដូចនេះ $f^{(99)}(x)=\frac{1}{10}$

(០៧) គេអោយបន្ទាត់ $L:x+y-9=0$ និងរង្វង់ $M:2x^2+2y^2-8x-8y-1=0$ ។ ចំណុច $A$ មួយនៅលើបន្ទាត់ $L$ និង ចំណុច $B,C$ នៅលើរង្វង់ $M$ ហើយ $\angle BAC=45^0$ ។ បន្ទាត់ $AB$ កាត់តាមផ្ចិតនៃរង្វង់ $M$ ។ រកវ៉ង់នៃអាប់ស៊ីស $x$ របស់ចំណុច $A$ ។

ដំណោះស្រាយ

ចំណុច $A$ នៅលើ $L:x+y-9=0$ នោះយើងយក $A(a,9-a)$

ចម្ងាយពីចំណុច $M$ ទៅបន្ទាត់ $AC$ គឺ $d=|AM|\times\sin\angle BAC$

$d=\sqrt{(a-2)^2+(9-a-2)^2}\times\sin 45^0$

$d=\sqrt{2a^2-18a+53}\times\frac{\sqrt{2}}{2}\quad(1)$

បន្ទាត់ $AC$ ប្រសព្វជាមួយរង្វង់ $M$ នោះ $d\le R$ ដែល $R$ ជាកាំនៃរង្វង់ $(2)$

រង្វង់ $M:x^2+y^2-4x-4y-\frac{1}{2}=0$

នោះ $M:(x-2)^2+(y-2)^2=\frac{17}{2}$

កាំរង្វង់ $R=\sqrt{\frac{17}{2}}\ (3)$

តាម $(1),(2)$ និង $(3)$ គេបាន $\sqrt{2a^2-18a+53}\times\frac{\sqrt{2}}{2}\le\sqrt{\frac{17}{2}}$

ដោះស្រាយវិសមីការនេះ គេបាន $3\le a\le 6$

ដូចនេះ វ៉ង់នៃអាប់ស៊ីស $x$ របស់ចំណុច គឺ $3\le a\le 6$

(០៨) វិសមភាព $f(n)=\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{2n+1}<a-2017\frac{1}{3}$ ពិតចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។ តើតម្លៃតូចបំផុតនៃចំនួនគត់ $a$ ស្មើនឹងប៉ុន្មាន ?

ដំណោះស្រាយ

អនុគមន៍ $f(n)=\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{2n+1}$ ម៉ូណូតូនចុះ

នោះ $f(1)$ ជាតម្លៃធំបំផុតនៃ $f(n)$

បើ $n=1$ នោះ $f(1)=\frac{1}{2}+\frac{1}{3}<a-2017\frac{1}{3}$

នាំអោយ $a>2018$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ដូចនេះ $a=2019$ ជាចំនួនគត់តូចបំផុត

**០៩** $P$ និង $Q$ ជាចំណុចនៅលើអេលីប $\frac{x^2}{a^2}+\frac{y^2}{b^2}=1\ ,(a>b>0)$ ផ្ទៀងផ្ទាត់ $OP\perp OQ$ ។ រកតម្លៃអតិបរមានៃផលគុណ $|OP|\times|OQ|$ ។

ដំណោះស្រាយ

យក $P\left(|OP|\cos\theta,|OP|\sin\theta\right)$ និង $Q\left(|OQ|\cos\left(\theta\pm\frac{\pi}{2}\right),|OQ|\sin\left(\theta\pm\frac{\pi}{2}\right)\right)$

យើងមាន $\frac{1}{OP^2}=\frac{\cos^2\theta}{a^2}+\frac{\sin^2\theta}{b^2}$ និង $\frac{1}{OQ^2}=\frac{\sin^2\theta}{a^2}+\frac{\cos^2\theta}{b^2}$

នាំអោយ $\frac{1}{OP^2}+\frac{1}{OQ^2}=\frac{1}{a^2}+\frac{1}{b^2}$

នោះផលគុណ $|OP|\times|OQ|$ មានតម្លៃអតិបរមា $\frac{2a^2b^2}{a^2+b^2}$ ពេល $|OP|=|OQ|=\sqrt{\frac{2a^2b^2}{a^2+b^2}}$

**១០** សមីការ $\lg kx=2\lg(x+1)$ មានរឹសតែមួយគត់ជាចំនួនគត់ ។ រកវ៉ង់នៃតម្លៃ $k$ ។

ដំណោះស្រាយ

យើងបាន $\begin{cases} kx>0 & (1)\\ x+1>0 & (2)\\ kx=(x+1)^2 & (3)\end{cases}$

តាម $(3)$ $x^2+(2-k)x+1=0$

រឹសទាំងពីរគឺ $x_1,x_2=\frac{1}{2}\left[k-2\pm\sqrt{k^2-4k}\right]$ ដែល $\Delta=k^2-4k\geq 0$

$k\leq 0$ រឺ $k\geq 4$

$(i)$ បើ $k<0$ នោះ $x_1+1>0,x_2+1<0$ ហើយ $kx_1>0$ ។ សមីការមានរឹសមួយ

$x_1=\frac{1}{2}\left[k-2+\sqrt{k^2-4k}\right]$

$(ii)$ បើ $k=4$ សមីការមានរឹសមួយ $x=1$

$(iii)$ បើ $k>0$ សមីការមានរឹសពីរ $x_1,x_2$ វិជ្ជមាន និង $x_1\neq x_2$ (មិនយក)

ដូចនេះ វ៉ង់តម្លៃ $k$ គឺ $k<0$ និង $k=4$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

**១១** បន្ទាត់ $l:y=kx+m$ ( $k,m$ ជាចំនួនគត់) ប្រសព្វជាមួយអេលីប $\frac{x^2}{16}+\frac{y^2}{12}=1$ ត្រង់ពីរចំណុចផ្សេងគ្នា $A$ និង $B$រួចប្រសព្វនឹងអ៊ីពែបូល $\frac{x^2}{4}-\frac{y^2}{12}=1$ ត្រង់ពីរចំណុចផ្សេងគ្នា $C$ និង $D$ ។ តើបន្ទាត់ $l$ អាចផ្ទៀងផ្ទាត់ $\overrightarrow{AC}+\overrightarrow{BD}=0$ ដែររឺទេ? បើអាច តើវាកើតឡើងបានប៉ុន្មានយ៉ាង? បើមិនអាច ចូរបញ្ជាក់មូលហេតុ?

ដំណោះស្រាយ

ចំពោះ $\begin{cases} y=kx+m \\ \frac{x^2}{16}+\frac{y^2}{12}=1 \end{cases}$

យើងបាន $\frac{x^2}{16}+\frac{(kx+m)^2}{12}=1$

នាំអោយ $\left(3+4k^2\right)x^2+8kmx+4m^2-48=0$

យក $A(x_1,y_1)$ និង $B(x_2,y_2)$ នោះ $x_1+x_2=-\frac{8km}{3+4k^2}$

$\Delta_1=(8km)^2-4\left(3+4k^2\right)\left(4m^2-48\right)>0 \quad (1)$

ចំពោះ $\begin{cases} y=kx+m \\ \frac{x^2}{4}-\frac{y^2}{12}=1 \end{cases}$

យើងបាន $\frac{x^2}{4}-\frac{(kx+m)^2}{12}=1$

នាំអោយ $\left(3-k^2\right)x^2-2kmx-m^2-12=0$

យក $C(x_3,y_3)$ និង $D(x_4,y_4)$ នោះ $x_3+x_4=\frac{2km}{3-k^2}$

$\Delta_2=(-2km)^2+4\left(3-k^2\right)\left(m^2+12\right)>0 \ (2)$

បើ $\overrightarrow{AC}+\overrightarrow{BD}=0$ នោះ $(x_4-x_2)+(x_3-x_1)=0$

នាំអោយ $x_1+x_2=x_3+x_4$

នាំអោយ $km=0$ ឬ $-\frac{4}{3+4k^2}=\frac{1}{3-k^2}$

• បើ $km=0$ នោះ $k=0$ឬ $m=0$

$a)$ បើ $k=0$ នោះតាម $(1)$ និង $(2)$ យើងបាន $-2\sqrt{3}<m<2\sqrt{3}$

តែ $m$ ជាចំនួនគត់ នោះ $m$ អាចយកតម្លៃ $-3,-2,-1,0,1,2,3$

$b)$ បើ $m=0$ នោះតាម $(1)$ និង $(3)$ យើងបាន $-\sqrt{3}<k<\sqrt{3}$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

តែ $k$ ជាចំនួនគត់ នោះ $k$ អាចយកតម្លៃ $-1,0,1$
ដូចនេះ មានបន្ទាត់ $l$ ចំនួន 9 ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

(១២) $p$ និង $q(q \neq 0)$ ជាចំនួនពិត ។ សមីការ $x^2 - px + q = 0$ មានរឹសពីរ $\alpha$ និង $\beta$ ។ ស្វ៊ីត $\{a_n\}$ ផ្ទៀងផ្ទាត់ $a_1 = p, a_2 = p^2 - q, a_n = pa_{n-1} - qa_{n-2}(n = 3,4,..)$ ។

ក) រកទម្រង់ទូទៅនៃ $\{a_n\}$ ជាអនុគមន៍នៃ $\alpha$ និង $\beta$ ។

ខ) បើ $p = 1, q = \frac{1}{4}$ រកផលបូក $n$ តួដំបូងនៃស្វ៊ីត $\{a_n\}$ ។

ដំណោះស្រាយ

ក) រកទម្រង់ទូទៅនៃ $\{a_n\}$ ជាអនុគមន៍នៃ $\alpha$ និង $\beta$

តាមទ្រឹស្តីបទវៀែត $\alpha + \beta = p, \alpha\beta = q \neq 0$

គេបាន $a_n = pa_{n-1} - qa_{n-2}$

$$= (\alpha + \beta)a_{n-1} - \alpha\beta a_{n-2} \; (n = 3,4,...)$$

គេអាចសរសេរ $a_n - \beta a_{n-1} = \alpha(a_{n-1} - \beta a_{n-2})$

តាង $b_n = a_{n+1} - \beta a_n$ នោះ $b_{n+1} = \alpha b_n \; (n = 1,2,...)$

ទំនាក់ទំនងនេះបញ្ជាក់ថា $(b_n)$ ជាស្វ៊ីតធរណីមាត្រដែលមានរេសុង $\alpha$ និងតួទី 1 គឺ

$$b_1 = a_2 - \beta a_1 = p^2 - q - \beta p = (\alpha + \beta)^2 - \alpha\beta - \beta(\alpha + \beta) = \alpha^2$$

នាំអោយ $b_n = \alpha^2 \times \alpha^{n-1} = \alpha^{n+1} \quad (1)$

នាំអោយ $a_{n+1} - \beta a_n = \alpha^{n+1}$ រឺ $a_{n+1} = \alpha^{n+1} + \beta a_n (n = 1,2,...)$

➢ បើ $\Delta = p^2 - 4q = 0$ យើងបាន $\alpha = \beta \neq 0, a_1 = p = 2\alpha$

នោះតាម $(1)$ $a_{n+1} = \alpha^{n+1} + \alpha a_n$ ឬ $\frac{a_{n+1}}{\alpha^{n+1}} - \frac{a_n}{\alpha_n} = 1$

នាំអោយ $\left\{\frac{a_n}{\alpha^n}\right\}$ ជាស្វ៊ីតនព្វន្តដែលមានផលសងរួម 1 និងតួទី 1 គឺ $\frac{a_1}{\alpha} = \frac{2\alpha}{\alpha} = 2$

គេបាន $\frac{a_n}{\alpha^n} = 2 + 1(n-1)$ នោះ $a_n = n + 1$

ដូចនេះ តួទូទៅនៃស្វ៊ីត $\{a_n\}$ គឺ $a_n = (n+1)\alpha^n \quad (2)$

➢ បើ $\Delta > 0, \alpha \neq \beta$ យើងបាន $a_{n+1} = \alpha^{n+1} + \beta a_n$

$$= \beta a_n + \frac{\beta}{\beta - \alpha}\alpha^{n+1} - \frac{\alpha}{\beta - \alpha}\alpha^{n+1} \; (n = 1,2,...)$$

គេបាន $a_{n+1} + \frac{\alpha^{n+2}}{\beta - \alpha} = \beta\left(a_n + \frac{\alpha^{n+1}}{\beta - \alpha}\right)$

នោះស្វ៊ីត $\left\{a_n+\frac{\alpha^{n+1}}{\beta-\alpha}\right\}$ ជាស្វ៊ីតធរណីមាត្រដែលមានរេសុង $\beta$ និងតួទី $1$ គឺ

$$a_1+\frac{\alpha^2}{\beta-\alpha}=\alpha+\beta+\frac{\alpha^2}{\beta-\alpha}=\frac{\beta^2}{\beta-\alpha}$$

នាំអោយ $a_n+\frac{\alpha^{n+1}}{\beta-\alpha}=\frac{\beta^2}{\beta-\alpha}\cdot\beta^{n-1}$

ដូចនេះ តួទូទៅនៃស្វ៊ីត $\{a_n\}$ គឺ $a_n=\frac{\beta^{n+1}-\alpha^{n+1}}{\beta-\alpha}\ (n=1,2,...)\quad(3)$

ខ) បើ $p=1,q=\frac{1}{4}$ រកផលបូក $n$ តួដំបូងនៃស្វ៊ីត $\{a_n\}$

បើ $p=1,q=\frac{1}{4}$ នោះ $\Delta=p^2-4q=0$ និង $\alpha=\beta=\frac{1}{2}$

តាម $(2)$ គេបាន $a_n=(n+1)\left(\frac{1}{2}\right)^n=\frac{n+1}{2^n}\ ,(n=1,2,3,...)$

ផលបូក $n$ តួដំបូងគឺ $S_n=\frac{2}{2}+\frac{3}{2^2}+\cdots+\frac{n+1}{2^n}$

$$\frac{1}{2}S_n=\frac{2}{2^2}+\frac{3}{2^3}+\cdots+\frac{n+1}{2^{n+1}}$$

គេបាន $\frac{1}{2}S_n=\frac{3}{2}-\frac{n+3}{2^{n+1}}$

ដូចនេះ $S_n=3-\frac{n+3}{2^n}$

**របៀបទី ០២ សម្រាប់សំនួរ ក)**

តាមទ្រឹស្តីបទវ្យែត $\alpha\times\beta=q\neq0,\alpha+\beta=p$ នោះ $a_1=\alpha+\beta,a_2=\alpha^2+\alpha\beta+\beta^2\quad(6)$

សមីការសំគាល់នៃស្វ៊ីត $\{a_n\}$ គឺ $\lambda^2-p\lambda+q=0$ ដែលមានរឹស $\alpha$ និង $\beta$

យើងអាចកំណត់តួទូទៅនៃ $\{a_n\}$ ដូចតទៅ ៖

$(i)$ បើ $\alpha=\beta\neq0$ , $a_n=(A_1+A_2n)\alpha^n$

តាម $(6)$ យើងបាន

$$(A_1+A_2)\alpha=2\alpha$$

$$(A_1+2A_2)\alpha^2=3\alpha^2$$

នាំអោយ $A_1=A_2=1$

ដូចនេះ តួទូទៅ $a_n=(n+1)\alpha^n$

$(ii)$ បើ $\alpha\neq\beta$ នោះ $a_n=A_1\alpha^n+A_2\beta^n$

តាម $(6)$ យើងបាន $A_1\alpha+A_2\beta=\alpha+\beta$

$$A_1\alpha^2+A_2\beta^2=\alpha^2+\alpha\beta+\beta^2$$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

នាំអោយ $A_1=\dfrac{-\alpha}{\beta-\alpha}$ និង $A_2=\dfrac{\beta}{\beta-\alpha}$

ដូចនេះ $a_n=\dfrac{-\alpha^{n+1}}{\beta-\alpha}+\dfrac{\beta^{n+1}}{\beta-\alpha}=\dfrac{\beta^{n+1}-\alpha^{n+1}}{\beta-\alpha}$

**១៣** រកតម្លៃអតិបរមា និង អប្បបរមានៃអនុគមន៍ $f(x)=\sqrt{x+27}+\sqrt{13-x}+\sqrt{x}$ ។

ដំណោះស្រាយ

ដែនកំណត់ $x\in[0;13]$

$$\begin{aligned}y&=\sqrt{x+27}+\sqrt{13-x}+\sqrt{x}\\&=\sqrt{x+27}+\sqrt{13+2\sqrt{x(13-x)}}\\&\geq\sqrt{27}+\sqrt{13}=3\sqrt{3}+\sqrt{13}\end{aligned}$$

នាំអោយ $\min(y)=3\sqrt{3}+\sqrt{13}$ ពេល $x=0$

ម្យ៉ាងទៀត តាមវិសមភាព Cauchy យើងបាន

$$\begin{aligned}y^2&=\left(\sqrt{x}+\sqrt{x+27}+\sqrt{13-x}\right)^2\\&\leq\left(\frac{1}{2}+1+\frac{1}{3}\right)\left[2x+(x+27)+3(13-x)\right]\\&=121\end{aligned}$$

នាំអោយ $\max(y)=121$ ពេល $4x=9(13-x)$ ឬ $x=9$

**១៤** រកវ៉ង់នៃអនុគមន៍ $f(x)=\sqrt{x-5}-\sqrt{24-3x}$ ។

ដំណោះស្រាយ

អនុគមន៍ $f(x)$ ជាអនុគមន៍កើនលើដែនកំណត់ $[5;8]$

វ៉ង់នៃអនុគមន៍ $f(x)$ គឺ $\left[-3;\sqrt{3}\right]$ ។

**១៥** អនុគមន៍ $y=\left(a\cos^2x-3\right)\sin x$ មានអប្បបរមាស្មើ $-3$ ។ រកវ៉ង់នៃចំនួនពិត $a$ ។

ដំណោះស្រាយ

តាង $\sin x=t$ នោះ $g(t)=\left(-at^2+a-3\right)t$

ឬ $g(t)=-at^3+(a-3)t$

ដោយ $-at^3+(a-3)t\geq-3$ (អនុគមន៍មានអប្បបរមាស្មើ $-3$)

យើងបាន $-at\left(t^2-1\right)-3(t-1)\geq0$

$$(t-1)\left(-at(t+1)-3\right)\geq0$$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ដោយ $t-1\le 0$ នោះ $-at(t+1)-3\le 0$

ឬ $a(t^2+t)\ge -3 \quad (1)$

ក) បើ $t=0,-1$ នោះ $(1)$ ពិតជានិច្ច

ខ) បើ $0<t\le 1$ នោះ $0<t^2+t\le 2$

គ) បើ $-1<t<0$ នោះ $-\frac{1}{4}\le t^2+t<0$

ដូចនេះ $-\frac{3}{2}\le a\le 12$

**១៦** រកចំនួនចំណុចគត់ (i.e. ចំណុចដែលមានអាប់ស៊ីស $x$ និង អរដោនេ $y$ ជាចំនួនគត់) ដែលមាននៅក្នុងតំបន់ហ៊ុំព័ទ្ធដោយមែកស្តាំនៃអ៊ីពែបូល $x^2-y^2=1$ និង បន្ទាត់ $x=100$ (មិនរាប់បញ្ចូលចំណុចនៅលើព្រំដែនឡើយ) ។

ដំណោះស្រាយ

មែកស្តាំរបស់អ៊ីពែបូលឆ្លុះគ្នាធៀបអ័ក្សអាប់ស៊ីស នោះយើងគិតទៅលើចំណុចគត់ផ្នែកខាងលើអ័ក្ស $x'ox$

យើងសន្មត់ថាបន្ទាត់ $y=k$ ប្រសព្វជាមួយមែកស្តាំអ៊ីពែបូល និង បន្ទាត់ $x=100$ រៀងគ្នាត្រង់ចំណុច $A_k$ និង $B_k$ $(k=1,2,3,\cdots,99)$ ។

ចំនួនចំណុចគត់នៅលើបណ្តាអង្កត់ $A_kB_k$ គឺ $99-k$

ដូច្នេះ ចំនួនចំណុចគត់នៅក្នុងផ្ទៃផ្នែកខាងលើអ័ក្សអាប់ស៊ីសមាន $\sum_{k=1}^{99}(99-k)=99\times 49=4851$

ដូចនេះ ចំនួនចំណុចគត់នៅក្នុងផ្ទៃសរុបមាន $2\times 4851+98=9800$

**១៧** $\{a_n\}$ ជាស្វ៊ីតនព្វន្តដែលមានផលសងរួមមិនសូន្យ និង $\{b_n\}$ ជាស្វ៊ីតធរណីមាត្រ។ ស្វ៊ីតទាំងពីរផ្ទៀងផ្ទាត់ $a_1=3,b_1=1,a_2=b_2,3a_5=b_3$ ។ គេដឹងថាមានចំនួនថេរ $\alpha$ និង $\beta$ ដែលចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ គេបាន $a_n=\log_\alpha b_n+\beta$ ។ ចូររក $\alpha+\beta$ ។

ដំណោះស្រាយ

តាង $d$ ជាផលសងរួមនៃស្វ៊ីត $\{a_n\}$ និង $q$ ជារេសុងនៃស្វ៊ីត $\{b_n\}$

យើងបាន $\begin{cases} 3+d=q & (1) \\ 3(3+4d)=q^2 & (2) \end{cases}$

យក $(1)$ ជំនួសចូល $(2)$ យើងបាន $9+12d=d^2+6d+9$

នាំអោយ $d=6$ និង $q=9$

នោះ $a_n=a_1+(n-1)d=3+(n-1)\times 6=6n-3$

នោះ $b_n=b_1.q^{n-1}=1.9^{n-1}$

តែ $a_n=\log_\alpha b_n+\beta$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

នោះ $6n-3=\log_{\alpha} 9^{n-1}+\beta$ ឬ $6n-3=(n-1)\log_{\alpha} 9+\beta$ ពិតចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

យក $n=1$ និង $n=2$ យើងបាន $\alpha=\sqrt[3]{3}$ , $\beta=3$

ដូចនេះ $\alpha+\beta=\sqrt[3]{3}+3$

**១៨** អនុគមន៍ $f(x)=a^{2x}+3a^{x}-2\ (a>0\ ,\ a\neq 1)$ មានតម្លៃអតិបរមាទៅដល់ 8 នៅក្នុងចន្លោះ $[-1,1]$ ។ រកតម្លៃអប្បបរមារបស់ $f$ នៅក្នុងចន្លោះ $[-1,1]$ ។

ដំណោះស្រាយ

តាង $a^{x}=y$ នោះអនុគមន៍ដើមក្លាយជា $g(y)=y^{2}+3y-2$

$g(y)$ ជាអនុគមន៍កើនលើ $\left(-\dfrac{3}{2};+\infty\right)$

បើ $0<a<1$ នោះ $y\in\left[a,a^{-1}\right]$ ហើយ $g(y)_{\max}=a^{-2}+3a^{-1}-2=8$

នាំអោយ $a^{-1}=2$ ឬ $a=\dfrac{1}{2}$

គេបាន $g(y)_{\min}=\left(\dfrac{1}{2}\right)^{2}+3\times\dfrac{1}{2}-2=-\dfrac{1}{4}$

បើ $a>1$ នោះ $y\in\left[a,a^{-1}\right]$ ហើយ $g(y)_{\max}=a^{2}+3a-2=2$

នាំអោយ $a=2$

គេបាន $g(y)_{\min}=2^{-2}+3\times 2^{-1}-2=-\dfrac{1}{4}$

សរុបមក តម្លៃអប្បបរមានៃ $f$ ក្នុងចន្លោះ $[-1,1]$ គឺ $-\dfrac{1}{4}$

**១៩** មនុស្សពីរនាក់បោះគ្រាប់ឡុកឡាក់ម្តងពីរគ្រាប់តាមលំដាប់ ។ អ្នកដែលបោះបានផលបូកលេខច្រើនជាង 6 មុនគេជាអ្នកឈ្នះ ។ រកប្រូបាបដែលអ្នកបោះដំបូងជាអ្នកឈ្នះ ។

ដំណោះស្រាយ

ប្រូបាបដែលបោះបានផលបូកលេខច្រើនជាង 6 គឺ $\dfrac{21}{36}=\dfrac{7}{12}$

ដូចនេះ ប្រូបាបដែលអ្នកដំបូងឈ្នះគឺ $\dfrac{7}{12}+\left(\dfrac{5}{12}\right)^{2}\times\dfrac{7}{12}+\left(\dfrac{5}{12}\right)^{4}\times\dfrac{7}{12}+\cdots=\dfrac{7}{12}\times\dfrac{1}{1-\dfrac{25}{144}}=\dfrac{12}{17}$

**២០** ប្រវែងទ្រនុងទាំង 9 នៃព្រីសត្រីមុខនិយ័ត $ABC-A_1B_1C_1$ ស្មើគ្នា ។ $P$ ជាចំណុចកណ្តាលនៃ $CC_1$ ហើយមុំទ្វេមុខ $B-A_1P-B_1=\alpha$ ។ រក $\sin\alpha$ ។

ដំណោះស្រាយ

យកអ័ក្សអាប់ស៊ីស $(x)$ ជាបន្ទាត់កាត់តាមអង្កត់ $AB$ ដែល $O$ ជាចំណុចកណ្តាល $AB$

យកអ័ក្សអរដោនេ $(y)$ ជាបន្ទាត់កាត់តាមអង្កត់ $OC$ ដើម្បីបង្កើតបានជាប្រព័ន្ធលំហកូអរដោនេចតុកោណ (ដូចរូប) ។




តាងប្រវែងទ្រនុងស្មើ 2 យើងបាន

$B(1,0,0)$, $B_1(1,0,2)$

$A_1(-1,0,2)$ , $P\left(0,\sqrt{3},1\right)$

គេបាន $\overrightarrow{BA_1}=(-2,0,2)$ , $\overrightarrow{BP}=\left(-1,\sqrt{3},\right.$

$\overrightarrow{B_1A_1}=(-2,0,0)$ , $\overrightarrow{B_1P}=\left(-1,\sqrt{3},-1\right)$

តាងវ៉ិចទ័រ $\vec{m}=(x_1,y_1,z_1)$ និង $\vec{n}=(x_2,y_2,z_2)$ កែងទៅនឹង $BA_1P$ និង $B_1A_1P$ រៀងគ្នា

គេបាន $\begin{cases}\vec{m}.\overrightarrow{BA_1}=-2x_1+2z_1=0,\\ \vec{m}.\overrightarrow{BP}=-x_1+\sqrt{3}y_1+z_1=0\end{cases}$

$\begin{cases}\vec{n}.\overrightarrow{B_1A_1}=-2x_2=0,\\ \vec{n}.\overrightarrow{B_1P}=-x_2+\sqrt{3}y_2-z_2=0\end{cases}$

យើងទាញបាន $\vec{m}=(1,0,1)$ និង $\vec{n}=(0,1,3)$

ដោយ $\left|\vec{m}.\vec{n}\right|=\left|\vec{m}\right|.\left|\vec{n}\right|.\left|\cos\alpha\right|$ នោះ $\sqrt{3}=\sqrt{2}.2.\left|\cos\alpha\right|$

នាំអោយ $\left|\cos\alpha\right|=\dfrac{\sqrt{6}}{4}$

ដូចនេះ $\sin\alpha=\dfrac{\sqrt{10}}{4}$

**របៀបទី ២**




យើងមាន $PC=PC_1, PA_1=PB$

តាង $O$ ជាប្រសព្វរវាង $A_1B$ និង $AB_1$

យើងបាន $OA_1=OB, OA=OB_1$ , $A_1B\perp AB_1$

ដោយ $PA=PB_1$ នោះ $PO\perp AB_1$

នាំអោយ $AB_1\perp(PA_1B)$

នៅក្នុងប្លង់ $(PA_1B)$ សង់បន្ទាត់ $OE\perp A_1P$

ភ្ជាប់ $B_1E$ នោះ $\angle B_1EO$ ជាប្លង់មុំនៃមុំទ្វេមុខ $B-A_1P-B_1$

សន្មត់យក $AA_1=2$ គេបាន $PB=PA_1=\sqrt{5}$

$, A_1O=B_1O=\sqrt{2}, PO=\sqrt{3}$

នៅក្នុងត្រីកោណ $PA_1O$ គេមាន $A_1O.PO = A_1P.OE$ ឬ $\sqrt{2}.\sqrt{3} = \sqrt{5}.OE$

នោះ $OE = \dfrac{\sqrt{6}}{\sqrt{5}}$

ដោយ $B_1O = \sqrt{2}$ នោះ $B_1E = \sqrt{B_1O^2 + OE^2} = \sqrt{2 + \dfrac{6}{5}} = \dfrac{4\sqrt{5}}{5}$

$$\sin\alpha = \sin\angle B_1EO = \frac{B_1O}{B_1E} = \frac{\sqrt{2}}{\frac{4\sqrt{5}}{5}} = \frac{\sqrt{10}}{4}$$

**២១** គេមាន $f(x) = ax^3 + bx^2 + cx + d\ (a \neq 0)$ ហើយ $|f'(x)| \leq 1$ ។ រកតម្លៃអតិបរមានៃ $a$ ។

ដំណោះស្រាយ

យើងបាន $f'(x) = 3ax^2 + 2bx + c$

នោះ $\begin{cases} f'(0) = c \\ f'\left(\dfrac{1}{2}\right) = \dfrac{3}{4}a + b + c \\ f'(1) = 3a + 2b + c \end{cases}$

នាំអោយ $3a = 2f'(0) + 2f'(1) - 4f'\left(\dfrac{1}{2}\right)$

នោះ $3|a| = \left|2f'(0) + 2f'(1) - 4f'\left(\dfrac{1}{2}\right)\right|$

$$\leq 2|f'(0)| + 2|f'(1)| + 4\left|f'\left(\frac{1}{2}\right)\right| \leq 8$$

នោះ $a \leq \dfrac{8}{3}$

ម្យ៉ាងទៀត $f(x) = \dfrac{8}{3}x^3 - 4x^2 + x + m$ ( $m$ ជាចំនួនថេរ ) ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលអោយមក

ដូចនេះ តម្លៃអតិបរមានៃ $a$ គឺ $\dfrac{8}{3}$

**របៀបទី ២**

តាង $g(x) = f'(x) + 1$ នោះ $0 \leq g(x) \leq 2$ ចំពោះ $0 \leq x \leq 1$

យក $z = 2x - 1$ នោះ $x = \dfrac{z+1}{2}$ ហើយ $-1 \leq z \leq 1$

តាង $h(z) = g\left(\dfrac{z+1}{2}\right) = \dfrac{3a}{4}z^2 + \dfrac{3a+2b}{2}z + \dfrac{3a}{4} + b + c + 1$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

គេសង្កេតឃើញថា $0\le h(z)\le 2$ និង $0\le h(-z)\le 2$ ចំពោះ $-1\le z\le 1$

នាំអោយ $0\le \dfrac{h(z)+h(-z)}{2}\le 2$ ចំពោះ $-1\le z\le 1$

នោះ $0\le \dfrac{3a}{4}z^2+\dfrac{3a}{4}+b+c+1\le 2$

យើងទាញបាន $\dfrac{3a}{4}+b+c+1\ge 0$ និង $\dfrac{3a}{4}z^2\le 2$

ដោយ $0\le z^2\le 1$ យើងបាន $a\le \dfrac{8}{3}$

ម្យ៉ាងទៀត $f(x)=\dfrac{8}{3}x^3-4x^2+x+m$ ( $m$ ជាចំនួនថេរ ) ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលអោយមក

ដូចនេះ តម្លៃអតិបរមានៃ $a$ គឺ $\dfrac{8}{3}$

**២២** គេអោយចំណុចចល័តពីរ $A(x_1,y_1)$ និង $B(x_2,y_2)$នៅលើខ្សែកោងប៉ារ៉ាបូល $y^2=6x$ ដែល $x_1+x_2=4$ ហើយ $x_1\ne x_2$ ។ មេដ្យាទ័រនៃអង្កត់ $AB$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $C$ ។ រកក្រឡាផ្ទៃធំបំផុតនៃ $\Delta ABC$ ។

ដំណោះស្រាយ

តាង $M$ ជាចំណុចកណ្តាលនៃ $AB$ ដែល $M(x_0,y_0)$ នោះ $x_0=\dfrac{x_1+x_2}{2}=2$ និង $y_0=\dfrac{y_1+y_2}{2}$

យើងបាន $k_{AB}=\dfrac{y_2-y_1}{x_2-x_1}=\dfrac{y_2-y_1}{\frac{y_2^2}{6}-\frac{y_1^2}{6}}=\dfrac{6}{y_1+y_2}=\dfrac{3}{y_0}$

សមីការមេដ្យាទ័រនៃអង្កត់ $AB$ គឺ $y-y_0=-\dfrac{y_0}{3}(x-2)\quad (1)$

ដោយមេដ្យាទ័រកាត់អ័ក្សអាប់ស៊ីសនត្រង់ $C$ នោះ $y=0, x=5$

នាំអោយ $C(5,0)$

តាម $(1)$ គេទាញបានសមីការបន្ទាត់ $AB$ គឺ $y-y_0=\dfrac{3}{y_0}(x-2)$ ឬ $x=\dfrac{y_0}{3}(y-y_0)+2\quad (2)$

យក $(2)$ ជំនួសចូល $y^2=6x$ គេបាន $y^2=2y_0(y-y_0)+12$

$y^2-2yy_0+2y_0^2-12=0\quad (3)$

ដោយ $y_1,y_2$ ជាឫសនៃសមីការ $(3)$ ហើយ $y_1\ne y_2$ យើងបាន

$\Delta=4y_0^2-4(2y_0^2-12)=-4y_0^2+48>0$

នោះ $-2\sqrt{3}<y_0<2\sqrt{3}$

យើងបាន



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ll




$$\begin{aligned}|AB| &= \sqrt{(x_1-x_2)^2+(y_1-y_2)^2}\\ &= \sqrt{\left(1+\left(\frac{y_0}{3}\right)^2\right)(y_1-y_2)^2}\\ &= \sqrt{\left(1+\frac{y_0^2}{9}\right)\left[(y_1+y_2)^2-4y_1y_2\right]}\\ &= \sqrt{\left(1+\frac{y_0^2}{9}\right)\left(4y_0^2-4\left(2y_0^2-12\right)\right)}\\ &= \frac{2}{3}\sqrt{\left(9+y_0^2\right)\left(12-y_0^2\right)}\end{aligned}$$

ចម្ងាយពីចំណុច $C(5,0)$ ទៅអង្គត់ $AB$ គឺ

$$h = |CM| = \sqrt{(5-2)^2+(0-y_0)^2} = \sqrt{9+y_0^2}$$

នាំអោយ $S_{\Delta ABC} = \frac{1}{2}|AB|.h = \frac{1}{3}\sqrt{\left(9+y_0^2\right)\left(12-y_0^2\right)}\cdot\sqrt{9+y_0^2}$

$$\begin{aligned}&= \frac{1}{3}\sqrt{\frac{1}{2}\left(9+y_0^2\right)\left(24-2y_0^2\right)\left(9+y_0^2\right)}\\ &\le \frac{1}{3}\sqrt{\frac{1}{2}\left(\frac{9+y_0^2+24-2y_0^2+9+y_0^2}{3}\right)^3}\\ &= \frac{14}{3}\sqrt{7}\end{aligned}$$

សមភាពកើតមានកាលណា $9+y_0^2 = 24-2y_0^2$ i.e. $y_0 = \pm\sqrt{5}$

យើងបាន $A\left(\frac{6+\sqrt{35}}{3},\sqrt{5}+\sqrt{7}\right)$, $B\left(\frac{6-\sqrt{35}}{3},\sqrt{5}-\sqrt{7}\right)$ និង

$A\left(\frac{6+\sqrt{35}}{3},-\left(\sqrt{5}+\sqrt{7}\right)\right), B\left(\frac{6-\sqrt{35}}{3},-\sqrt{5}+\sqrt{7}\right)$

ដូចនេះ តម្លៃអតិបរមានៃក្រឡាផ្ទៃត្រីកោណ $ABC$ គឺ $\frac{14}{3}\sqrt{7}$

**របៀបទី ០២**

មេដ្យាទ័រនៃអង្គត់ $AB$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $C(5;0)$

តាង $x_1 = t_1^2, x_2 = t_2^2, t_1 > t_2, t_1^2 + t_2^2 = 4$

ក្រឡាផ្ទៃត្រីកោណ $ABC$ គឺ $S_{\Delta ABC}=\frac{1}{2}\begin{vmatrix}5 & 0 & 1\\ t_1^2 & \sqrt{6}t_1 & 1\\ t_2^2 & \sqrt{6}t_2 & 1\end{vmatrix}$

នោះ $S_{\Delta ABC}^2=\left(\frac{1}{2}\left(5\sqrt{6}t_1+\sqrt{6}t_1^2t_2-\sqrt{6}t_1t_2^2-5\sqrt{6}t_2\right)\right)^2$

$$=\frac{3}{2}(t_1-t_2)^2(t_1t_2+5)^2$$

$$=\frac{3}{2}(4-2t_1t_2)^2(t_1t_2+5)(t_1t_2+5)$$

$$\le\frac{3}{2}\left(\frac{14}{3}\right)^3$$

នាំអោយ $S_{\Delta ABC}\le\frac{14}{3}\sqrt{7}$

សមភាពកើតមានកាលណា $(t_1-t_2)^2=t_1t_2+5$ និង $t_1^2+t_2^2=4$

គេបាន $t_1=\frac{\sqrt{7}+\sqrt{5}}{\sqrt{6}}$ និង $t_2=-\frac{\sqrt{7}-\sqrt{5}}{\sqrt{6}}$

នាំអោយ $A\left(\frac{6+\sqrt{35}}{3},\sqrt{5}+\sqrt{7}\right)$, $B\left(\frac{6-\sqrt{35}}{3},\sqrt{5}-\sqrt{7}\right)$ និង

$A\left(\frac{6+\sqrt{35}}{3},-\left(\sqrt{5}+\sqrt{7}\right)\right),B\left(\frac{6-\sqrt{35}}{3},-\sqrt{5}+\sqrt{7}\right)$

ដូចនេះ តម្លៃអតិបរមានៃក្រឡាផ្ទៃត្រីកោណ $ABC$ គឺ $\frac{14}{3}\sqrt{7}$

**២៣** ស្រាយបញ្ជាក់ថាសមីការ $2x^3+5x-2=0$ មានរឹសតែមួយគត់តាងដោយ $r$ ហើយមានស្វ៊ីតកើនដាច់ខាតតែមួយគត់ដែលផ្ទៀងផ្ទាត់ $\frac{2}{5}=r^{a_1}+r^{a_2}+r^{a_3}+\cdots$ ។

ដំណោះស្រាយ

តាង $f(x)=2x^3+5x-2$ នោះ $f'(x)=6x^2+5>0$

មានន័យថា $f(x)$ ជាអនុគមន៍កើនដាច់ខាត

ម្យ៉ាងទៀត $f(0)=-2<0$ និង $f\left(\frac{1}{2}\right)=\frac{3}{4}>0$

នេះបញ្ជាក់ថាសមីការ $2x^3+5x-2=0$ មានរឹសតែមួយគត់ $r\in\left(0,\frac{1}{2}\right)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ដោយ $r$ ជាឫសនៃសមីការ $2x^3+5x-2=0$ នោះ $2r^3+5r-2=0$

យើងបាន $\frac{2}{5}=\frac{r}{1-r^3}=r+r^4+r^7+r^{10}+\cdots$

នោះស្វ៊ីត $a_n=3n-2\ (n=1,2,\cdots)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលសួររក

ឧបមាថាមានស្វ៊ីតចំនួនគត់វិជ្ជមានពីរ $a_1<a_2<\cdots<a_n<\cdots$ និង $b_1<b_2<\cdots<b_n<\cdots$ ដែលផ្ទៀងផ្ទាត់ $r^{a_1}+r^{a_2}+r^{a_3}+\cdots=r^{b_1}+r^{b_2}+r^{b_3}+\cdots=\frac{2}{5}$

សម្រួលតួណាដែលកើតមាននៅអង្គទាំងពីរនៃកន្សោមខាងលើ គេបាន

$r^{s_1}+r^{s_2}+r^{s_3}+\cdots=r^{t_1}+r^{t_2}+r^{t_3}+\cdots$ ដែល $s_i$ និង $t_1$ ខុសពីគ្នា

យើងឧបមាដែរថា $s_1<t_1$ នោះ $r^{s_1}<r^{s_1}+r^{s_2}+\cdots=r^{t_1}+r^{t_2}+\cdots$

$$1<r^{t_1-s_1}+r^{t_2-s_1}+\cdots\le r+r^2+\cdots$$
$$=\frac{1}{1-r}-1<\frac{1}{1-\frac{1}{2}}-1$$

នាំអោយ $1<1$ ផ្ទុយពីការពិត

ដូចនេះ $\{a_n\}$ ជាស្វ៊ីតកើនដាច់ខាតតែមួយគត់

**(២៤)** តាងសំណុំ $A=\{a_1,a_2,a_3,a_4\}$ ។ គេដឹងថា សំណុំនៃផលបូកធាតុនៃសំណុំរងដែលមានបីធាតុ (ternary subsets) កើតចេញពីសំណុំ $A$ គឺ $B=\{-1,3,5,8\}$ ។ ចូររកសំណុំ $A$ ។

ដំណោះស្រាយ

សំណុំរងមានបីធាតុ នោះមានធាតុបីនៃសំណុំ $A$ កើតឡើងនៅក្នុងសំណុំរងទាំងនោះ

គេបាន $3(a_1+a_2+a_3+a_4)=(-1)+3+5+8=15$

ឬ $a_1+a_2+a_3+a_4=5$

ធាតុទាំងបួននៃសំណុំ $A$ មាន $5-(-1)=6, 5-3=2, 5-5=0$ និង $5-8=-3$

ដូចនេះ សំណុំ $A=\{-3,0,2,6\}$

**(២៥)** $a$ និង $b$ ជាចំនួនពិតដែល $\frac{1}{a}+\frac{1}{b}\le 2\sqrt{2}$ និង $(a-b)^2=4(ab)^3$ ។

កំណត់ $\log_a b$ ។

ដំណោះស្រាយ

ដោយ $\frac{1}{a}+\frac{1}{b}\le 2\sqrt{2}$ នោះ $a+b\le 2\sqrt{2}ab$

តែ $(a+b)^2=4ab+(a-b)^2=4ab+4(ab)^3$
$$\ge 4.2\sqrt{ab.(ab)^3}=8(ab)^2$$

នាំអោយ $a+b\geq 2\sqrt{2}ab$ (1)

គេបាន $a+b=2\sqrt{2}ab$ (2)

តាម $(1)$ សមភាពកើតមានកាលណា $ab=1$ ហើយតាម $(2)$ យើងអាចរកបាន

$\begin{cases}a=\sqrt{2}-1\\ b=\sqrt{2}+1\end{cases}$ និង $\begin{cases}a=\sqrt{2}+1\\ b=\sqrt{2}-1\end{cases}$

ដូចនេះ $\log_a b=-1$

**២៦** គេមានវិសមភាព $\cos^5\theta-\sin^5\theta<7\left(\sin^3\theta-\cos^3\theta\right)$, $\theta\in[0;2\pi)$ ។

រកវ៉ង់នៃ $\theta$ ។

ដំណោះស្រាយ

តាមវិសមភាព $\cos^5\theta-\sin^5\theta<7\left(\sin^3\theta-\cos^3\theta\right)$

យើងបាន $\sin^3\theta+\frac{1}{7}\sin^5\theta>\cos^3\theta+\frac{1}{7}\cos^5\theta$

ដោយ $f(x)=x^3+\frac{1}{7}x^5$ កើនលើ $(-\infty;+\infty)$

នោះ $\sin\theta>\cos\theta$ ឬ $2k\pi+\frac{\pi}{4}<\theta<2k\pi+\frac{5\pi}{4}\ (k\in Z)$

តែ $\theta\in[0;2\pi)$ នោះវ៉ង់នៃ $\theta$ គឺ

**២៧** សិស្ស 7 នាក់នឹងត្រូវបានគណៈកម្មការកីឡារៀបចំអោយចូលរួមកម្មវិធីប្រកួត 5 ប្រភេទ ។ គេតម្រូវថា សិស្ស $A$ និង $B$ មិនអាចចូលរួមកម្មវិធីតែមួយទេ ។ គ្រប់កម្មវិធីប្រកួតត្រូវតែមានសិស្សយ៉ាងតិចម្នាក់ចូលរួម ។ សិស្សនិមួយៗត្រូវតែចូលរួមប្រកួតអោយបានមួយកម្មវិធី ហើយតែមួយកម្មវិធីគត់ ។ តើមានប៉ុន្មានរបៀបដើម្បីរៀបគម្រោងអោយត្រូវនឹងលក្ខខណ្ឌខាងលើនេះ ?

ដំណោះស្រាយ

មានពីរករណីដែលអាចរៀបចំបាន ដើម្បីអោយត្រូវចលក្ខខណ្ឌខាងលើ

$(i)$. មានកម្មវិធីប្រកួតមួយ ដែលចូលរួមប្រកួតដោយសិស្សបីនាក់

ក្នុងករណីនេះគេបាន $C_7^3.5!-C_5^1.5!=3600$

$(ii)$. មានកម្មវិធីប្រកួតពីរ ដែលកម្មវិធីនិមួយៗចូលរួមដោយសិស្សពីររូប

ក្នុងករណីនេះ គេបាន $\frac{1}{2}\left(C_7^2.C_5^2\right).5!-C_5^2.5!=11400$

ដូចនេះ គម្រោងសរុបដែលអាចរៀបបានគឺ $3600+11400=15000$ របៀប

**២៨** គេមានតេត្រាអ៊ែត $ABCD$ ។ គេដឹងថា $\angle ADB=\angle BDC=\angle CDA=60^0$, $AD=BD=3$ និង $CD=2$ ។ រករង្វាស់កាំនៃស្វ៊ែរចារិកក្រៅ $ABCD$ ។




ដំណោះស្រាយ

តាង $O$ ជាផ្ចិតរង្វង់ចារិកក្រៅ $ABCD$

នោះ $O$ ស្ថិតនៅលើបន្ទាត់ឈរនៃប្លង់ $ABD$ កាត់តាម

$N$ ជាផ្ចិតរង្វង់ចារិកក្រៅ $\Delta ABD$

គេដឹងថា ត្រីកោណ $ABD$ សម័ង្ស នោះ $N$ ជាផ្ចិត

តាង $P$ និង $N$ ជាំណុចកណ្តាលនៃ $AB$ និង $CD$ រៀងគ្នា

នោះ $N$ នៅលើ $DP$ ដែល $ON \perp DP$ និង $OM \perp CD$

តាង $\theta$ ជាមុំកំណត់ដោយបន្ទាត់ $CD$ និងប្លង់ $(ABD)$

គេមាន $\angle CDA = \angle CDB = \angle ADB = 60^0$

គេបាន $\cos\theta = \dfrac{1}{\sqrt{3}}, \sin\theta = \dfrac{\sqrt{2}}{\sqrt{3}}$

ដោយ $DM = \dfrac{1}{2}CD = 1, DN = \dfrac{2}{3}\cdot DP = \dfrac{2}{3}\cdot\dfrac{\sqrt{3}}{2}\cdot 3 = \sqrt{3}$

អនុវត្តទ្រឹស្តីបទកូស៊ីនុស ក្នុងត្រីកោណ $DMN$ យើងបាន

$$MN^2 = DM^2 + DN^2 - 2\cdot DM\cdot DN\cdot\cos\theta$$

$$= 1^2 + \left(\sqrt{3}\right)^2 - 2.1.\sqrt{3}.\frac{1}{\sqrt{3}} = 2$$

$MN = \sqrt{2}$ នោះកាំស្វ៊ែរចារិកក្រៅ $ABCD$ គឺ $OD = \dfrac{MN}{\sin\theta} = \dfrac{\sqrt{2}}{\frac{\sqrt{2}}{\sqrt{3}}} = \sqrt{3}$

ដូចនេះ $R = \sqrt{3}$

**២៩** $ABCD$ ជាចតុកោណប៉ោងដែលមាន $\angle B + \angle D < 180^0$ (ដូចរូប) ។ $P$ ជាចំណុចមួយចល័ត នៅក្នុងប្លង់ ។ តាង $f(P) = PA\times BC + PD\times CA + PC\times AB$ ។




ក) ស្រាយបញ្ជាក់ថា $P, A, B, C$ នៅលើរង្វង់តែមួយកាលណា $f(P)$ ខិតទៅរកតម្លៃអប្បរមា ។

ខ) $E$ ជាចំណុចមួយនៅលើធ្នូ $AB$ នៃរង្វង់ផ្ចិត $O$ ដែលចារិកក្រៅត្រីកោណ $ABC$ ដែលផ្ទៀងផ្ទាត់ $\frac{AE}{AB}=\frac{\sqrt{3}}{2},\frac{BC}{EC}=\sqrt{3}-1,\angle ECB=\frac{1}{2}\angle ECA$ ហើយ $DA,DC$ ប៉ះនឹងរង្វង់ផ្ចិត $O$ ប្រវែង $AC=\sqrt{2}$ ។ រកតម្លៃអប្បបរមានៃ $f(P)$ ។

ដំណោះស្រាយ

ក) ស្រាយបញ្ជាក់ថា $P,A,B,C$ នៅលើរង្វង់តែមួយកាលណា $f(P)$ ខិតទៅរកតម្លៃអប្បរមា

តាមរូប យើងប្រើវិសមភាព Ptolemy គឺ $PA\times BC+PC\times AB\geq PB\times AC$

នោះ $f(P)=PA\times BC+PC\times AB+PD\times AC$

$\geq PB\times CA+PD\times CA$

$=(PB+PD)\times CA$

សមភាពកើតមានកាលណាចំណុច $P,A,B,C$ នៅលើរង្វង់ផ្ចិត $O$ ហើយ $P$ នៅលើធ្នូ $AC$ $(1)$

ម្យ៉ាងទៀត $PB+PD\geq BD$ សមភាពកើតមានកាលណា $P$ នៅលើបន្ទាត់ $BD$ $(2)$

តាម $(1)$ និង $(2)$ យើងបាន $f(P)_{\min}=BD\times CA$

ដូចនេះ $P,A,B,C$ នៅលើរង្វង់តែមួយកាលណា $f(P)$ ខិតទៅរកតម្លៃអប្បរមា

ខ) រកតម្លៃអប្បបរមានៃ $f(P)$

តាង $\angle ECB=\alpha$ នោះ $\angle ECA=2\alpha$

តាមទ្រឹស្តីបទស៊ីនុស យើងបាន $\frac{AE}{AB}=\frac{\sin 2\alpha}{\sin 3\alpha}=\frac{\sqrt{3}}{2}$

នោះ $\sqrt{3}\sin 3\alpha=2\sin 2\alpha$

$\sqrt{3}\left(3\sin\alpha-4\sin^3\alpha\right)=4\sin\alpha\cos\alpha$

សម្រួលរួចយើងបាន $3\sqrt{3}-4\sqrt{3}\left(1-\cos^2\alpha\right)-4\cos\alpha=0$

ឬ $4\sqrt{3}\cos^2\alpha-4\cos\alpha-\sqrt{3}=0$

គេបាន $\cos\alpha=\frac{\sqrt{3}}{2}$ និង $\cos\alpha=-\frac{1}{2\sqrt{3}}$ (មិនយក)

នាំអោយ $\alpha=30^0$ និង $\angle ECA=60^0$

ម្យ៉ាងទៀត $\frac{BC}{EC}=\sqrt{3}-1=\frac{\sin\left(\angle EAC-30^0\right)}{\sin\angle EAC}$

នោះ $\frac{\sqrt{3}}{2}\sin\angle EAC-\frac{1}{2}\cos\angle EAC=\left(\sqrt{3}-1\right)\sin\angle EAC$

$\frac{2-\sqrt{3}}{2}\sin\angle EAC=\frac{1}{2}\cos\angle EAC$

នាំអោយ $\tan\angle EAC = \dfrac{1}{2-\sqrt{3}} = 2+\sqrt{3}$

យើងបាន $\angle EAC = 75^0$ និង $\angle AEC = 45^0$

ដោយត្រីកោណ $ADC$ សមបាត និង $AC=\sqrt{2}$ យើងបានត្រីកោណសមបាត $ABC$ ដែលមាន $BC=\sqrt{2}$ និង $AB=2$

គេមាន $BD^2 = AB^2 + AD^2 = 4+1=5$

$BD=5$

នាំអោយ $f(P)_{\min} = BD\times CA = \sqrt{5}\times\sqrt{2} = \sqrt{10}$

**៣០** $f(x)$ ជាអនុគមន៍ខួបដែលមានខួប $T$ និង $1$ ហើយ $0<T<1$ ។
ស្រាយបញ្ជាក់ថា ៖

ក) បើ $T$ ជាចំនួនសនិទាន នោះមានចំនួនបឋម $p$ មួយដែល $\dfrac{1}{p}$ ជាខួបនៃ $f(x)$ ។

ខ) បើ $T$ ជាចំនួនអសនិទាន នោះមានស្វ៊ីតនៃចំនួនអសនិទាន $\{a_n\}$ មួយផ្ទៀងផ្ទាត់ $1>a_n>a_{n+1}>0\ (n=1,2,\cdots)$ ហើយ $a_n$ និមួយៗជាខួបនៃ $f(x)$ ។

ដំណោះស្រាយ

ក) បើ $T$ ជាចំនួនសនិទាន នោះមានចំនួនបឋម $p$ មួយដែល $\dfrac{1}{p}$ ជាខួបនៃ $f(x)$

$T$ ជាចំនួនសនិទាន នោះ $T=\dfrac{m}{n}$ ដែល $m,n$ ជាចំនួនគត់វិជ្ជមាន និង $(m,n)=1$

មានពីរចំនួនគត់ $a$ និង $b$ ដែល $ma+nb=1$

គេបាន $\dfrac{1}{m} = \dfrac{ma+nb}{m} = a\times 1 + b\times T$ ក៏ជាខួបនៃ $f(x)$

ម្យ៉ាងទៀត $m\ge 2$ ព្រោះ $0<T<1$

នោះ $m=pm'$ ដែល $p$ ជាចំនួនបឋម

នាំអោយ $\dfrac{1}{p} = m'\times\dfrac{1}{m}$ ជាខួបនៃអនុគមន៍ $f(x)$

ខ) បើ $T$ ជាចំនួនអសនិទាន នោះមានស្វ៊ីតនៃចំនួនអសនិទាន $\{a_n\}$ មួយផ្ទៀងផ្ទាត់ $1>a_n>a_{n+1}>0\ (n=1,2,\cdots)$ ហើយ $a_n$ និមួយៗជាខួបនៃ $f(x)$

បើ $T$ អសនិទាន គេតាង $a_1 = 1-\left[\dfrac{1}{T}\right]\times T$

នោះ $0<a_1<1$ និង $a_1$ អសនិទាន

យើងកំណត់ទំនាក់ទំនងកំណើន $a_{n+1} = 1-\left[\dfrac{1}{a_n}\right]\times a_n$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

តាមកំណើន $a_n$ និមួយៗអសនិទាន និង $o<a_n<1$

ម្យ៉ាងទៀត $\frac{1}{a_n}-\left[\frac{1}{a_n}\right]<1$

គេបាន $1<a_n+\left[\frac{1}{a_n}\right]\times a_n$

នោះ $a_{n+1}=1-\left[\frac{1}{a_n}\right]\times a_n<a_n$

ស៊ីត $\{a_n\}$ ជាស៊ីតចុះ

យើងអាចស្រាយតាមនិយមន័យនៃ $\{a_n\}$ និងតាមវិចារកំណើន $a_n$ និមួយៗជាខួបនៃ $f(x)$

(៣១) $M,N$ ជាចំណុចកណ្ដាលនៃធ្នូ $BC,AC$ រៀងគ្នា (មើលរូប) ដែលនៅលើរង្វង់ចារឹកក្រៅត្រីកោណមានមុំស្រួច $ABC$ $(\angle A<\angle B)$ ។ តាមចំណុច $C$ គូស $PC\parallel MN$ ប្រសព្វជាមួយរង្វង់ $\Gamma$ ត្រង់ចំណុច $P$ ។ $I$ ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ $ABC$ ។ បន្លាយ $PI$ អោយជួប $\Gamma$ ត្រង់ចំណុច $T$ ។




ក) ស្រាយបញ្ជាក់ថា $MP\times MT=NP\times NT$ ។

ខ) $Q$ ជាចំណុចសេរី $(\neq A,T,B)$ នៅលើធ្នូ $AB$ (មិនមានចំណុច $C$) តាងផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ $\Delta AQC,\Delta QCB$ ដោយ $I_1,I_2$ រៀងគ្នា ។ ស្រាយបញ្ជាក់ថា $Q,I_1,I_2,T$ ស្ថិតនៅលើរង្វង់តែមួយ ។

ដំណោះស្រាយ



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II




ភ្ជាប់ $NI$ និង $MI$

ដោយ $PC \parallel MN$ ហើយ $P, C, M, N$ នៅលើរង្វង់តែមួយ នោះ $PCMN$ ជាចតុកោណព្នាយសមបាត

នាំអោយ $NP = MC, PM = NC$

ភ្ជាប់ $AM, CI$ នោះ $AM$ ប្រសព្វ $CI$ ត្រង់ $I$

យើងបាន $\angle MIC = \angle MAC + \angle ACI$

$$= \angle MCB + \angle BCI$$

$$= \angle MCI$$

នាំអោយ $MC = MI$

ដូចគ្នាដែរ $NC = NI$

គេបាន $NP = MI, PM = NI$ នោះ $MPNI$ ជាប្រលេឡូក្រាម

$S_{\Delta PMT} = S_{\Delta PNT}$ (បាតនិងកម្ពស់រួម)

ម្យ៉ាងទៀត $\angle TNP + \angle PMT = 180^0$ នោះ $P, N, T, M$ នៅលើរង្វង់តែមួយ

យើងបាន $S_{\Delta PMT} = \frac{1}{2} PM \times MT \sin \angle PMT$

$$= S_{\Delta PNT} = \frac{1}{2} PN \times NT \sin \angle PNT$$

$$= \frac{1}{2} PN \times NT \sin \angle PMT$$

ដូចនេះ $MP \times MT = NP \times NT$

ខ) ស្រាយបញ្ជាក់ថា $Q, I_1, I_2, P$ នៅលើរង្វង់តែមួយ




យើងមាន $\angle NCI_1 = \angle NCA + \angle ACI_1$

$= \angle NQC + \angle QCI_1 = \angle CI_1N$

នាំអោយ $NC = NI_1$

ដូចគ្នាដែរ $MC = MI_2$

តាមសំនួរ ក) យើងដឹងថា $MP = NC, NP = MC$ នោះ $\frac{NT}{NI_1} = \frac{MT}{MI_2}$

នាំអោយ $\angle I_1NT = \angle QNT = \angle QMT = \angle I_1MT$

គេបាន $\Delta I_1NT \sim \Delta I_2MT$

វិបាក $\angle NTI_1 = \angle MTI_2$

យើងបាន $\angle I_1QI_2 = \angle NQM = \angle NTM = \angle I_1TI_2$

ដូចនេះ ចំណុច $Q, I_1, I_2, T$ នៅលើរង្វង់តែមួយ

**៣២** បន្ទាត់ $x - 2y - 1 = 0$ និងបារ៉ាបូល $y^2 = 4x$ កាត់គ្នាត្រង់ពីរចំណុច $A$ និង $B$ ។ ចំណុច $C$ នៅលើប៉ារ៉ាបូល ហើយ $\angle ACB = 90^0$ ។ រកកូអរដោនេនៃចំណុច $C$ ។

ដំណោះស្រាយ

តាង $A(x_1, y_1), B(x_2, y_2)$ និង $C(t^2, 2t)$

សមីការអាប់ស៊ីសចំណុចប្រសព្វរវាងបន្ទាត់ និង ប៉ារ៉ាបូលគឺ

$$y^2 - 8y - 4 = 0$$

នោះ $y_1 + y_2 = 8, y_1.y_2 = -4$

ដោយ $x_1 = 2y_1 + 1$, $x_2 = 2y_2 + 1$

$x_1 + x_2 = 2(y_1 + y_2) + 2 = 18$

$x_1.x_2 = 4y_1y_2 + 2(y_1 + y_2) + 1 = 1$

ម្យ៉ាងទៀត $\angle ACB = 90^0$ នោះ $\overrightarrow{CA}.\overrightarrow{CB} = 0$

នាំអោយ $\left(t^2-x_1\right)\left(t^2-x_2\right)+\left(2t-y_1\right)\left(2t-y_2\right)=0$

$t^4-\left(x_1+x_2\right)t^2+x_1\cdot x_2+4t^2-2\left(y_1+y_2\right)t+y_1\cdot y_2=0$

$t^4-14t^2-16t-3=0$

$\left(t^2+4t+3\right)\left(t^2-4t-1\right)=0$

តែ $t^2-4t-1\neq 0$ ហើយបើ $t^2-2.2t-1=0$ នោះចំណុច $C$ នៅលើបន្ទាត់ $x-2y-1=0$ ហើយអាចត្រួតស៊ីគ្នាជាមួយនឹង $A$ ឬ $B$ ដែលជាករណីមិនអាច

គេបាន $t^2+4t+3=0$

$t_1=-1,t_2=-3$

ដូចនេះ កូអរដោនេចំណុច $C(1,-2)$ ឬ $C(9,-6)$

**៣៣** គេអោយ $a,b,c,x,y,z$ ជាចំនួនពិតវិជ្ជមានដែល $a+b+c=x+y+z$ និង $abc=xyz$ ។ ឧបមាថា $a\leq x<y<z\leq c$ និង $a<b<c$ ។ ស្រាយបញ្ជាក់ថា $a=x,b=y$ និង $c=z$ ។

ដំណោះស្រាយ

តាង $f(t)=(t-x)(t-y)(t-z)-(t-a)(t-b)(t-c)$

នោះ $f(t)=kt$ ដែល $k$ ជាចំនួនថេរ

គេមាន $ka=f(a)=(a-x)(a-y)(a-z)\leq 0$

$kc=f(c)=(c-x)(c-y)(c-z)\geq 0$

នាំអោយ $k=0$ ហើយ $f(a)=f(c)=0$

គេទាញបាន $a=x,c=z$ និង $b=y$

**៣៤** គេមាន $f(x)=\left|\lg(x+1)\right|$ ហើយចំនួនពិត $a$ និង $b\ (a<b)$ ផ្ទៀងផ្ទាត់ $f(a)=f\left(-\dfrac{b+1}{b+2}\right)$ , $f(10a+6b+21)=4\lg 2$ ។ ចូររកតម្លៃ $a$ និង $b$ ។

ដំណោះស្រាយ

គេមាន $f(a)=f\left(-\dfrac{b+1}{b+2}\right)$

នោះ $\left|\lg(a+1)\right|=\left|\lg\left(-\dfrac{b+1}{b+2}+1\right)\right|=\left|\log\left(\dfrac{1}{b+2}\right)\right|=\left|\lg(b+2)\right|$

គេទាញបាន $a+1=b+2$ រឺ $(a+1)(b+2)=1$

តែ $a<b$ នោះ $a+1\neq b+2$

នាំអោយ $(a+1)(b+2)=1$

ដោយ $0<a+1$ ព្រោះ $f(a)=\left|\lg(a+1)\right|$

នោះ $0<a+1<b+1<b+2$

នាំអោយ $0<a+1<a<b+2$

គេបាន $(10a+6b+21)+1=10(a+1)+6(b+2)$

$$=6(b+2)+\frac{10}{b+2}>1$$

នោះ $f(10a+6b+21)=\left|\log\left[6(b+2)+\frac{10}{b+2}\right]\right|$

$$=\lg\left[6(b+2)+\frac{10}{b+2}\right]$$

តែ $\lg\left[6(b+2)+\frac{10}{b+2}\right]=4\lg 2$

យើងបាន $6(b+2)+\frac{10}{b+2}=16$ នោះ $b=-\frac{1}{3}$ និង $b=-1$ (មិនយក)

ចំពោះ $b=-\frac{1}{3}$ នោះ $a=-\frac{2}{5}$

ដូចនេះ $a=-\frac{2}{5}$ , $b=-\frac{1}{3}$

**៣៥** ស្វ៊ីត $\{a_n\}$ ផ្ទៀងផ្ទាត់ $a_1=2t-3\ (t\in R, t\neq 1)$ ដែល

$$a_{n+1}=\frac{(2t^{n+1}-3)a_n+2(t-1)t^n-1}{a_n+2t^n-1}\ (n\in N^*)$$ ។

ក) រករូបមន្តតួទី $n$ នៃ $\{a_n\}$ ។

ខ) បើ $t>0$ តើមួយណាធំជាងរវាង $a_{n+1}$ និង $a_n$ ។

ដំណោះស្រាយ

ក) រករូបមន្តតួទី $n$ នៃ $\{a_n\}$

គេអាចសរសេរ $a_{n+1}=\frac{2(t^{n+1}-1)(a_n-1)}{a_n+2t^n-1}-1$

នោះ $\frac{a_{n+1}+1}{t^{n+1}-1}=\frac{2(a_n+1)}{a_n+2t^n-1}=\frac{\frac{2(a_n+1)}{t^n-1}}{\frac{a_n+1}{t^n-1}+2}$

តាង $\frac{a_n+1}{t^n-1}=b_n$ នោះ $b_{n+1}=\frac{2b_n}{b_n+2}$ ដែល $b_1=\frac{a_1+1}{t-1}=\frac{2t-2}{t-1}=2$

ម្យ៉ាងទៀត $\frac{1}{b_{n+1}}=\frac{1}{b_n}+\frac{1}{2},\ \frac{1}{b_1}=\frac{1}{2}$

$$\frac{1}{b_n}=\frac{1}{b_1}+(n-1)\cdot\frac{1}{2}=\frac{n}{2}$$

នាំអោយ $\frac{a_n+1}{t^n-1}=\frac{n}{2}$

ដូចនេះ $$a_n=\frac{2\left(t^n-1\right)}{n}-1$$

ខ) ប្រៀបធៀប $a_{n+1}$ និង $a_n$

យើងបាន $$a_{n+1}-a_n=\frac{2\left(t^{n+1}-1\right)}{n+1}-\frac{2\left(t^n-1\right)}{n}$$

$$=\frac{2(t-1)}{n(n+1)}\left[n\left(1+t+\cdots+t^{n-1}+t^n\right)-(n+1)\left(1+t+\cdots+t^{n-1}\right)\right]$$

$$=\frac{2(t-1)}{n(n+1)}\left[nt^n-\left(1+t+\cdots+t^{n-1}\right)\right]$$

$$=\frac{2(t-1)}{n(n+1)}\left[\left(t^n-1\right)+\left(t^n-t\right)+\cdots+\left(t^n-t^{n-1}\right)\right]$$

$$=\frac{2(t-1)^2}{n(n+1)}\left[\left(t^{n-1}+\cdots+t+1\right)+t\left(t^{n-2}+\cdots+t+1\right)+\cdots+t^{n-1}\right]$$

ចំពោះ $t>0$ និង $t\neq 1$ គេបាន $a_{n+1}-a_n>0$

ដូចនេះ $a_{n+1}$ ធំជាង $a_n$

**៣៦** បន្ទាត់ $l$ មួយមានមេគុណប្រាប់ទិសស្មើ $\frac{1}{3}$ ប្រសព្វ អេលីប $C:\frac{x^2}{36}+\frac{y^2}{4}=1$ ត្រង់ ពីរចំណុច $A$ និង $B$ ។ ចំណុច $P\left(3\sqrt{2},\sqrt{2}\right)$ នៅខាងលើផ្នែកខាងឆ្វេងនៃបន្ទាត់ $l$ ( ដូចមានក្នុងរូប) ។




ក) ស្រាយបញ្ជាក់ថាផ្ចិតរង្វង់ចារិកក្នុងត្រីកោណ $\Delta PAB$ ស្ថិតនៅលើបន្ទាត់មួយ ។

ខ) បើ $\angle APB=60^0$ ចូររកក្រឡាផ្ទៃ $\Delta APB$ ។

ដំណោះស្រាយ



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ll

ក) ស្រាយបញ្ជាក់ថាផ្ចិតរង្វង់ចារិកក្នុងត្រីកោណ $\Delta PAB$ ស្ថិតនៅលើបន្ទាត់មួយ

តាងបន្ទាត់ $(l): y=\frac{1}{3}x+m$ និងចំណុច $A(x_1,y_1),B(x_2,y_2)$

សមីការអាប់ស៊ីសចំណុចប្រសព្វរវាង $(l)$ និង អេលីប $C$ គឺ

$$2x^2+6mx+9m^2-36=0$$

នោះ $x_1+x_2=-3m,\ x_1x_2=\frac{9m^2-36}{2},\ k_{PA}=\frac{y_1-\sqrt{2}}{x_1-3\sqrt{2}}$ និង $k_{PB}=\frac{y_2-\sqrt{2}}{x_2-3\sqrt{2}}$

គេបាន $k_{PA}+k_{PB}=\frac{y_1-\sqrt{2}}{x_1-3\sqrt{2}}+\frac{y_2-\sqrt{2}}{x_2-3\sqrt{2}}$

$$=\frac{\left(y_1-\sqrt{2}\right)\left(x_2-3\sqrt{2}\right)+\left(y_2-\sqrt{2}\right)\left(x_1-3\sqrt{2}\right)}{\left(x_1-3\sqrt{2}\right)\left(x_2-3\sqrt{2}\right)}$$

នៅក្នុងកន្សោមខាងលើ ភាគយកគឺ

$$\left(\frac{1}{3}x_1+m-\sqrt{2}\right)\left(x_2-3\sqrt{2}\right)+\left(\frac{1}{3}x_2+m-\sqrt{2}\right)\left(x_1-3\sqrt{2}\right)$$

$$=\frac{2}{3}x_1x_2+\left(m-2\sqrt{2}\right)(x_1+x_2)-6\sqrt{2}\left(m-\sqrt{2}\right)$$

$$=\frac{2}{3}\cdot\frac{9m^2-36}{2}+\left(m-2\sqrt{2}\right)(-3m)-6\sqrt{2}\left(m-\sqrt{2}\right)$$

$$=3m^2-12-3m^2+6\sqrt{2}m-6\sqrt{2}m+12=0$$

នាំអោយ $k_{PA}+k_{PB}=0$

ដោយចំណុច $P$ ស្ថិតនៅផ្នែកខាងលើឆ្វេងបន្ទាត់ $l$ នោះកន្លះបន្ទាត់ពុះមុំ $\angle APB$ ស្របនឹងអ័ក្ស $y'oy$

ដូចនេះ ផ្ចិតរង្វង់ចារិកក្នុងត្រីកោណ $APB$ នៅលើបន្ទាត់ $x=3\sqrt{2}$

ខ) បើ $\angle APB=60^0$ រកក្រឡាផ្ទៃ $\Delta APB$

បើ $\angle APB=60^0$ តាមសំនួរ ក) យើងបាន $k_{PA}=\sqrt{3},k_{PB}=-\sqrt{3}$

សមីការបន្ទាត់ $(PA): y-\sqrt{2}=\sqrt{3}\left(x-3\sqrt{2}\right)$

យកជំនួសចូល $\frac{x^2}{36}+\frac{y^2}{4}=1$ រួចបំបាត់ $y$ គេបាន

$$14x^2+9\sqrt{6}\left(1-3\sqrt{3}\right)x+18\left(13-3\sqrt{3}\right)=0$$

ដែលមានរឹស $x_1$ និង $3\sqrt{2}$

ដោយ $x_1.3\sqrt{2}=\frac{18\left(13-3\sqrt{3}\right)}{14}$ នោះ $x_1=\frac{3\sqrt{2}\left(13-3\sqrt{3}\right)}{14}$

យើងបាន $|PA|=\sqrt{1+\left(\sqrt{3}\right)^2}.\left|x_1-3\sqrt{2}\right|=\dfrac{3\sqrt{2}\left(3\sqrt{3}+1\right)}{7}$

ដូចគ្នាដែរ $|PB|=\dfrac{3\sqrt{2}\left(3\sqrt{3}-1\right)}{7}$

$$S_{\Delta APB}=\frac{1}{2}\cdot|PA|.|PB|.\sin 60^0$$
$$=\frac{1}{2}\cdot\frac{3\sqrt{2}\left(3\sqrt{3}+1\right)}{7}\cdot\frac{3\sqrt{2}\left(3\sqrt{3}-1\right)}{7}\cdot\frac{\sqrt{3}}{2}$$
$$=\frac{117\sqrt{3}}{49}$$

ដូចនេះ $S_{\Delta APB}=\dfrac{117\sqrt{3}}{49}$

**៣៧** $P$ ជាចំណុចមួយនៅលើរូបភាពនៃ $y=x+\dfrac{2}{x}\ (x>0)$ ។ តាមចំណុច $P$ គូសបន្ទាត់មួយកែងនឹង $y=x$ និងអ័ក្ស $y$ ដោយមាន $A$ និង $B$ ជាជើងនៃចំណោលកែងរៀងគ្នា ។ កំណត់តម្លៃ $\overrightarrow{PA}.\overrightarrow{PB}$ ។

ដំណោះស្រាយ

តាង $P\left(x_0,x_0+\dfrac{2}{x_0}\right)$

សមីការបន្ទាត់ $(PA): y-y_0=m(x-x_0)$

ដោយបន្ទាត់ $(PA)$ កែងនឹង $y=x$ នោះ $m\cdot 1=-1$ ឬ $m=-1$

គេបាន $(PA): y-\left(x_0+\dfrac{2}{x_0}\right)=-(x-x_0)$

$$y=-x+2x_0+\frac{2}{x_0}$$

បន្ទាត់ $(PA): y=-x+2x_0+\dfrac{2}{x_0}$ កែង $y=x$ ត្រង់ $A$

នោះកូអរដោនេចំណុច $A$ ជាចម្លើយនៃសមីការ $-x+2x_0+\dfrac{2}{x_0}=x$

នាំអោយ $x=x_0+\dfrac{1}{x_0}$

នោះចំណុច $A\left(x_0+\dfrac{1}{x_0},x_0+\dfrac{1}{x_0}\right)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ចំណុច $B\left(0, x_0 + \dfrac{2}{x_0}\right)$




$$\overrightarrow{PA} = \left(\frac{1}{x_0}, -\frac{1}{x_0}\right) \text{ និង } \overrightarrow{PB} = (-x_0, 0)$$

$$\overrightarrow{PA}.\overrightarrow{PB} = \left(\frac{1}{x_0}\right)(-x_0) + \left(-\frac{1}{x_0}\right)(0) = -1$$

ដូចនេះ $\overrightarrow{PA}.\overrightarrow{PB} = -1$

**របៀបទី ២**

ចម្ងាយពីចំណុច $P\left(x_0, x_0 + \dfrac{2}{x_0}\right)$ ទៅបន្ទាត់ $y = x$

និងអ័ក្ស $y$ គឺ $|PA| = \dfrac{\left|x_0 - \left(x_0 + \dfrac{2}{x_0}\right)\right|}{\sqrt{2}} = \dfrac{\sqrt{2}}{x_0}$

ហើយ $|PB| = x_0$

ដោយ $O, A, P$ និង $B$ ជាចំណុចនៅលើរង្វង់ នោះ $\angle APB = \pi - \angle AOB = \dfrac{3\pi}{4}$

$$\overrightarrow{PA}.\overrightarrow{PB} = \left|\overrightarrow{PA}\right|.\left|\overrightarrow{PB}\right|.\cos\frac{3\pi}{4} = -1$$

**៣៨** $A, B, C$ ជាមុំនៃ $\Delta ABC$ ដែលត្រូវនឹងជ្រុង $a, b, c$ ហើយផ្ទៀងផ្ទាត់សមីការ $a\cos B - b\cos A = \dfrac{3}{5}c$ ។ កំណត់តម្លៃ $\dfrac{\tan A}{\tan B}$ ។

ដំណោះស្រាយ

**របៀបទី ១**

គេមានសមីការ $a\cos B - b\cos A = \dfrac{3}{5}c$

$$a \cdot \frac{c^2 + a^2 - b^2}{2ca} - b \cdot \frac{b^2 + c^2 - a^2}{2bc} = \frac{3}{5}c$$

ឬ $a^2 - b^2 = \dfrac{3}{5}c^2$

នាំអោយ $\dfrac{\tan A}{\tan B} = \dfrac{\sin A.\cos B}{\sin B.\cos A} = \dfrac{a \cdot \dfrac{c^2 + a^2 - b^2}{2ca}}{b \cdot \dfrac{b^2 + c^2 - a^2}{2bc}}$

$$=\frac{c^2+a^2-b^2}{b^2+c^2-a^2}=\frac{\frac{8}{5}c^2}{\frac{2}{5}c^2}=4$$

**របៀបទី ២**




តាម $C$ គូស $CD\perp AB$ ដែលមានជើងចំណោល $D$

យើងបាន $a\cos B=DB$ និង $b\cos A=AD$

តាមសម្មតិកម្ម $DB-AD=\frac{3}{5}c$

ហើយ $DB+AD=c$

នាំអោយ $AD=\frac{1}{5}c$ និង $DB=\frac{4}{5}c$

គេបាន $\frac{\tan A}{\tan B}=\frac{\frac{CD}{AD}}{\frac{CD}{BD}}=\frac{BD}{AD}=4$

**របៀបទី ៣**

តាមទ្រឹស្តីបទចំណោលកែង $a\cos B+b\cos A=c$

តែ $a\cos B-b\cos A=\frac{3}{5}c$

នោះ $a\cos B=\frac{4}{5}c$ និង $b\cos A=\frac{1}{5}c$

គេបាន $\frac{\tan A}{\tan B}=\frac{\sin A\cos B}{\sin B\cos A}=\frac{a.\cos B}{b.\cos A}=\frac{\frac{4}{5}c}{\frac{1}{5}c}=4$

**៣៩** គេអោយ $x,y,z\in[0,1]$ ។ រកតម្លៃអតិបរមានៃ $M=\sqrt{y-x}+\sqrt{z-y}+\sqrt{z-x}$ ។

ដំណោះស្រាយ

យើងសន្មត់ថា $0\le x\le y\le z\le 1$

ដោយ $\sqrt{y-x}+\sqrt{z-y}\le\sqrt{2\left[(y-x)+(z-y)\right]}=\sqrt{2(z-x)}$

យើងបាន $M\le\sqrt{2(z-x)}+\sqrt{z-x}=\left(\sqrt{2}+1\right)\sqrt{z-x}\le\sqrt{2}+1$

សមភាពកើតមានកាលណា $y-x=z-y, x=0, z=1$ (i.e. $x=0, y=\frac{1}{2}, z=1$)

ដូចនេះ $M_{\max}=\sqrt{2}+1$

**៤០** $f(x)$ ជាអនុគមន៍សេសនៅលើ $R$ ហើយ $f(x)=x^2$ ចំពោះ $x\geq 0$ ។ ឧបមាថាចំពោះ $x\in[a,a+2]$ , $f(x+a)\geq 2f(x)$ ។ រកវែងនៃចំនួនពិត $a$ ។

ដំណោះស្រាយ

តាមលក្ខខណ្ឌដែលអោយមក យើងអាចយក $f(x)$ ដូចខាងក្រោម

$$f(x)=\begin{cases} x^2 & (x\geq 0) \\ -x^2 & (x<0) \end{cases}$$

នោះ $2f(x)=f\left(\sqrt{2}x\right)$

វិសមីការដើមក្លាយជា $f(x+a)\geq f\left(\sqrt{2}x\right)$

ដោយ $f(x)$ កើនលើ $R$ នោះ $x+a\geq\sqrt{2}x$

i.e. $a\geq\left(\sqrt{2}-1\right)x$

ម្យ៉ាងទៀត $x\in[a,a+2]$ នោះ $\left(\sqrt{2}-1\right)x$ មានតម្លៃអតិបរមាដល់ $\left(\sqrt{2}-1\right)(a+2)$ កាលណា

$x=a+2$

នាំអោយ $a\geq\left(\sqrt{2}-1\right)(a+2)$

$$a\geq\sqrt{2}$$

ដូចនេះ $a\in\left[\sqrt{2},+\infty\right]$

**៤១** រកផលបូកនៃគ្រប់ចំនួនពិតវិជ្ជមាន $n$ ផ្ទៀងផ្ទាត់ $\frac{1}{4}<\sin\frac{\pi}{n}<\frac{1}{3}$ ។

ដំណោះស្រាយ

គេមាន $\sin x$ ជាអនុគមន៍ផតចំពោះ $x\in\left(0,\frac{\pi}{6}\right)$

យើងបាន $\frac{3}{\pi}x<\sin x<x$

$$\sin\frac{\pi}{13}<\frac{\pi}{13}<\frac{1}{4}\ ,\ \sin\frac{\pi}{12}>\frac{3}{\pi}\times\frac{\pi}{12}=\frac{1}{4}$$

$$\sin\frac{\pi}{10}<\frac{\pi}{10}<\frac{1}{3}\ ,\ \sin\frac{\pi}{9}>\frac{3}{\pi}\times\frac{\pi}{9}=\frac{1}{3}$$

នោះ $\sin\frac{\pi}{13}<\frac{1}{4}<\sin\frac{\pi}{12}<\sin\frac{\pi}{11}<\sin\frac{\pi}{10}<\frac{1}{3}<\sin\frac{\pi}{9}$

ចំនួនគត់ $n$ ដែលផ្ទៀងផ្ទាត់មាន 10,11,12

ដូចនេះ ផលបូកគឺ 33

(៤២) ក) គណនា $I=\int_0^{\frac{1}{2}}\frac{x^4}{x^2-1}dx$ ។

ខ) តាង $I(t)=\int_0^{t}\frac{\tan^4 x}{\cos 2x}dx \quad \left(0<t<\frac{\pi}{4}\right)$ ។

ទាញរក $I(t)$ រួចស្រាយបញ្ជាក់វិសមភាព $\tan\left(t+\frac{\pi}{4}\right)>e^{\frac{2}{3}\left(\tan^3 t+3\tan t\right)}$ ចំពោះ $0<t<\frac{\pi}{4}$ ។

ដំណោះស្រាយ

ក) គណនា $I=\int_0^{\frac{1}{2}}\frac{x^4}{x^2-1}dx$

យើងបាន $I=\int_0^{\frac{1}{2}}\left(\frac{x^4-1}{x^2-1}+\frac{1}{x^2-1}\right)dx$

$$=\int_0^{\frac{1}{2}}\left(x^2+1\right)dx+\frac{1}{2}\int_0^{\frac{1}{2}}\left(\frac{1}{x-1}-\frac{1}{x+1}\right)dx$$

$$=\frac{1}{3}\left[x^3\right]_0^{\frac{1}{2}}+\frac{1}{2}+\frac{1}{2}\left[\ln\left|\frac{x-1}{x+1}\right|\right]_0^{\frac{1}{2}}$$

$$=\frac{1}{3}\left(\frac{1}{8}-0\right)+\frac{1}{2}+\frac{1}{2}\left(\ln\frac{1}{3}-0\right)$$

$$=\frac{13}{24}-\frac{1}{2}\ln 3$$

ដូចនេះ $I=\frac{13}{24}-\frac{1}{2}\ln 3$

ខ) ទាញរក $I(t)$ រួចស្រាយបញ្ជាក់វិសមភាព $\tan\left(t+\frac{\pi}{4}\right)>e^{\frac{2}{3}\left(\tan^3 t+3\tan t\right)}$ ចំពោះ $0<t<\frac{\pi}{4}$

តាង $u=\tan x$ នោះ $du=\left(1+\tan^2 x\right)dx$

$x=0\Rightarrow u=0$

$x=t\Rightarrow u=\tan t$

យើងបាន $I(t)=\int_0^{t}\frac{\tan^4 x}{\frac{1-\tan^2 x}{1+\tan^2 x}}\cdot\frac{1}{1+\tan^2 x}\left(1+\tan^2 x\right)dx$

$$=\int_0^{t}\frac{\tan^4 x}{1-\tan^2 x}\cdot\left(1+\tan^2 x\right)dx$$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

នោះ $I(t)=\int_0^{\tan t}\frac{u^4}{1-u^2}du=-\int_0^{\tan t}\frac{u^4}{u^2-1}du$

$$=-\int_0^{\tan t}\left(u^2+1+\frac{1}{u^2-1}\right)du$$

$$=-\int_0^{\tan t}\left(u^2+1\right)du-\frac{1}{2}\int_0^{\tan t}\left(\frac{1}{u-1}-\frac{1}{u+1}\right)du$$

$$=-\frac{1}{3}\left[u^3\right]_0^{\tan t}-\tan t-\frac{1}{2}\left[\ln\left|\frac{u-1}{u+1}\right|\right]_0^{\tan t}$$

តាម $(1)$ និង $(2)$ គេបាន $ab.IA.IB=2c^2\sin\frac{A}{2}\sin\frac{B}{2}\cos\frac{A}{2}\cos\frac{B}{2}(l_A.l_B)$

$4R^2\sin A\sin B.IA.IB=2R^2\sin A\sin B(l_A.l_B)$ (ព្រោះ $C=2R$ )

នាំអោយ $l_A.l_B=2IA.IB$ ពិត

**៨៨** ក) គេអោយ $u>0,v>0$ ស្រាយបញ្ជាក់ថា $\frac{u^2+v^2}{u+v}\geq\frac{u+v}{2}$ ។

តើពេលណាទើបសញ្ញា $(=)$ កើតមាន?

ខ) គេអោយ $x,y,z>0$ ។ តាង $S=\frac{x^2}{x+y}+\frac{y^2}{y+z}+\frac{z^2}{z+x}$ និង

$T=\frac{y^2}{x+y}+\frac{z^2}{y+z}+\frac{x^2}{z+x}$ ។ ចូរស្រាយថា $S=T$ និងទាញឲ្យបាន $S\geq\frac{x+y+z}{2}$ ។

ដំណោះស្រាយ

ក) ស្រាយបញ្ជាក់ថា $\frac{u^2+v^2}{u+v}\geq\frac{u+v}{2}$

តាមវិសមភាព Bunhiyacopsky យើងបាន

$$|(u.1+v.1)|\leq\sqrt{1^2+1^2}\cdot\sqrt{u^2+v^2}$$

$$(u+v)^2\leq 2(u^2+v^2)$$

ដោយ $u>0,v>0$ គេបាន $\frac{u^2+v^2}{u+v}\geq\frac{u+v}{2}$ ពិត

ខ) ស្រាយថា $S=T$ និងទាញឲ្យបាន $S\geq\frac{x+y+z}{2}$

យើងបាន $S-T=\frac{x^2-y^2}{x+y}+\frac{y^2-z^2}{y+z}+\frac{z^2-x^2}{z+x}$

$$=x-y+y-z+z-x=0$$

នាំអោយ $S=T$ ពិត

យើងបាន $S+T=\frac{x^2+y^2}{x+y}+\frac{y^2+z^2}{y+z}+\frac{z^2+x^2}{z+x}$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

$$\geq \frac{x+y}{2}+\frac{y+z}{2}+\frac{z+x}{2}$$

នាំអោយ $2S \geq x+y+z$

$$S \geq \frac{x+y+z}{2}$$ ពិត

**៨៩** ស្រាយបញ្ជាក់ថាសមីការ $15x^2-7y^2=9$ គ្មានចម្លើយជាចំនួនគត់ទេ ។

ដំណោះស្រាយ

ឧបមាថាសមីការ $15x^2-7y^2=9$ មានចម្លើយ

នោះ $y=3y_1$

គេបានសមីការថ្មី $15x^2-63y_1^2=9$

$$5x^2-21y^2=3$$

នោះ $x=3x_1$

គេបាន $45x_1^2-21y_1^2=3$

$$15x_1^2-7y_1^2=1$$

$\Rightarrow y_1^2 \equiv -1 \pmod 3$ ផ្ទុយពីការពិត ព្រោះ $y_1^2 \equiv 0 \pmod 3$ ឬ $y_1^2 \equiv 1 \pmod 3$

ដូចនេះ សមីការ $15x^2-7y^2=9$ មានចម្លើយជាចំនួនគត់ទេ

**៩០** $ABC$ ជាត្រីកោណកែងត្រង់ $C$ ។ $M_1$ និង $M_2$ ជាចំណុចសេរីនៅក្នុងត្រីកោណ $ABC$ ។ $M$ ជាចំណុចកណ្តាលនៃ $M_1M_2$ ។ បន្លាយនៃ $BM_1, BM$ និង $BM_2$ ប្រសព្វ $AC$ ត្រង់ $N_1, N$ និង $N_2$ រៀងគ្នា ។ ស្រាយបញ្ជាក់ថា $\frac{M_1N_1}{BM_1}+\frac{M_2N_2}{BM_2} \geq 2\frac{MN}{BM}$ ។

ដំណោះស្រាយ




តាង $H_1, H_2, H$ ជាជើងនៃចំណោលកែងនៃ $M_1, M_2, M$ រៀងគ្នាមកលើជ្រុង $BC$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

គេបាន $\dfrac{M_1N_1}{BM_1}=\dfrac{H_1C}{BH_1}$ , $\dfrac{M_2N_2}{BM_2}=\dfrac{H_2C}{BH_2}$

$$\frac{MN}{BM}=\frac{HC}{BH}=\frac{H_1C+H_2C}{BH_1+BH_2}$$

យើងកំណត់យក $BC=1, BH_1=x, BH_2=y$ យើងបាន

$$\frac{M_1N_1}{BM_1}=\frac{H_1C}{BH_1}=\frac{1-x}{x}$$

$$\frac{M_2N_2}{BM_2}=\frac{H_2C}{BH_2}=\frac{1-y}{y}$$

នាំអោយ $\dfrac{MN}{BM}=\dfrac{HC}{BH}=\dfrac{1-x+1-y}{x+y}$

យើងត្រូវស្រាយថា $\dfrac{1-x}{x}+\dfrac{1-y}{y}\ge 2\dfrac{1-x+1-y}{x+y}$ ឬ $\dfrac{1}{x}+\dfrac{1}{y}\ge\dfrac{4}{x+y}$

$(x-y)^2\ge 0$ ពិត

ដូចនេះ $\dfrac{M_1N_1}{BM_1}+\dfrac{M_2N_2}{BM_2}\ge 2\dfrac{MN}{BM}$

**៩១** ក) ស្រាយបញ្ជាក់ថា $\ln k\le\int_k^{k+1}\ln x dx\le\ln(k+1)$ , $k>0$ ។

ខ) ចំពោះចំនួនគត់វិជ្ជមាន $n\ge 1$ ស្រាយថា $(n-1)!\le n^n e^{1-n}<n!$ ។

គ) គេដឹងថា $\lim\limits_{n\to\infty}\sqrt[n]{a}=\lim\limits_{n\to\infty}\sqrt[n]{n}=1$ ដែល $a>0$ ។

ទាញរក $\lim\limits_{n\to\infty}\dfrac{\sqrt[n]{n!}}{n}$ ។

ដំណោះស្រាយ

ក) ស្រាយបញ្ជាក់ថា $\ln k\le\int_k^{k+1}\ln x dx\le\ln(k+1)$ , $k>0$

ចំពោះ $k\le x\le k+1$ គេបាន $\ln k\le\ln x\le\ln(k+1)$

នាំអោយ $\int_k^{k+1}\ln k dx\le\int_k^{k+1}\ln x dx\le\int_k^{k+1}\ln(k+1)dx$

$$\ln k[x]_k^{k+1}\le\int_k^{k+1}\ln x dx\le\ln(k+1)[x]_k^{k+1}$$

$$\ln k\left[(k+1)-k\right]\le\int_k^{k+1}\ln x dx\le\ln(k+1)(k+1-k)$$

នាំអោយ $\ln k \le \int_k^{k+1} \ln x dx \le \ln(k+1)$ , $k>0$ ពិត

ខ) ចំពោះចំនួនគត់វិជ្ជមាន $n \ge 1$ ស្រាយថា $(n-1)! \le n^n e^{1-n} < n!$

យើងមាន $\ln k \le \int_k^{k+1} \ln x dx \le \ln(k+1)$ , $k>0$

អោយតម្លៃ $k = 1, 2, \cdots, n-1$

$$\begin{cases} \ln 1 \le \int_1^2 \ln x dx \le \ln 2 \\ \ln 2 \le \int_2^3 \ln x dx \le \ln 3 \\ \ln 3 \le \int_3^4 \ln x dx \le \ln 4 \\ \dots\dots\dots\dots\dots\dots \\ \ln(n-1) \le \int_{n-1}^{n} \ln x dx \le \ln n \end{cases}$$

បូកបញ្ចូលគ្នាយើងបាន $\ln 1 + \ln 2 + \cdots + \ln(n-1) \le \int_1^n \ln x dx \le \ln 2 + \ln 3 + \cdots + \ln n$

$$\ln(n-1)! \le \int_1^n \ln x dx \le \ln n! \quad (1)$$

តែ $\int_1^n \ln x dx = \left[ x \ln x - x \right]_1^n = n(\ln n - 1) + 1$

តាម $(1)$ គេបាន $\ln(n-1)! \le n \ln + 1 - n \le \ln n!$

$$\ln(n-1)! \le \ln\left(n^n . e^{1-n}\right) \le \ln n!$$

នាំអោយ $(n-1)! \le n^n . e^{1-n} \le n!$ ពិត

គ) ទាញរក $\lim_{n\to\infty} \frac{\sqrt[n]{n!}}{n}$

គេមាន $(n-1)! \le n^n . e^{1-n} \le n!$ នោះ $\frac{n!}{n^n} \cdot \frac{1}{n} \le e^{1-n} \le \frac{n!}{n^n}$

ចំពោះ $\frac{n!}{n^n} \cdot \frac{1}{n} \le e^{1-n}$ នោះ $\frac{n!}{n^n} \le \frac{ne}{e^n}$

នាំអោយ $\frac{\sqrt[n]{n!}}{n^n} \le \frac{\sqrt[n]{ne}}{e}$

គេបាន $\lim_{n\to\infty}\frac{\sqrt[n]{n!}}{n^n}=\lim_{n\to\infty}\frac{\sqrt[n]{ne}}{e}=\frac{1}{e}\quad(2)$

ចំពោះ $\frac{n!}{n^n}\geq\frac{e}{e^n}$ នោះ $\frac{\sqrt[n]{n!}}{n^n}\geq\frac{\sqrt[n]{e}}{e}$

គេបាន $\lim_{n\to\infty}\frac{\sqrt[n]{n!}}{n^n}\geq\lim_{n\to\infty}\frac{\sqrt[n]{e}}{e}=\frac{1}{e}\ (4)$

តាម $(2)$ និង $(3)$ យើងបាន $\lim_{n\to\infty}\frac{\sqrt[n]{n!}}{n^n}=\frac{1}{e}$

**៩២** គេអោយអនុគមន៍ $f(x)=\frac{4x-2}{(x^2+1)(x+2)}$ ។

ក) រកពីរចំនួនពិត $a$ និង $b$ ដើម្បីអោយ $f(x)=\frac{2ax}{x^2+1}-\frac{b}{x+2}$ ។

ខ) ចំពោះតម្លៃ $a$ និង $b$ ដែលរកឃើញ ចូរគណនា $\lim_{\varepsilon\to\infty}\int_0^{\varepsilon}f(x)dx$ ។

ដំណោះស្រាយ

ក) រកពីរចំនួនពិត $a$ និង $b$ ដើម្បីអោយ $f(x)=\frac{2ax}{x^2+1}-\frac{b}{x+2}$

យើងបាន $f(x)=\frac{2ax(x+2)-(x+2)(x^2+1)}{(x^2+1)(x+2)}$

$$=\frac{(2a-b)x^2+4ax-b}{(x^2+1)(x+2)}$$

តែ $f(x)=\frac{2ax}{x^2+1}-\frac{b}{x+2}$

គេទាញបាន $\begin{cases}2a-b=0\\4a=4\\b=2\end{cases}$

ដូចនេះ $a=1$ និង $b=2$

ខ) ចំពោះតម្លៃ $a$ និង $b$ ដែលរកឃើញ ចូរគណនា $\lim_{\varepsilon\to\infty}\int_0^{\varepsilon}f(x)dx$

ចំពោះ $a=1,b=2$ គេបាន $f(x)=\frac{2x}{x^2+1}-\frac{2}{x+2}$

នោះ $\int_0^{\varepsilon} f(x)dx = \int_0^{\varepsilon}\left(\frac{2x}{x^2+1} - \frac{2}{x+2}\right)dx$

$$= \left[\ln(x^2+1) - 2\ln(x+2)\right]_0^{\varepsilon}$$

$$= \ln\frac{x^2+1}{(x+2)^2}\Big|_0^{\varepsilon}$$

$$= \ln\frac{\varepsilon^2+1}{(\varepsilon+2)^2} - \ln\frac{1}{4} = \ln\frac{4(\varepsilon^2+1)}{(\varepsilon+2)^2}$$

ដូចនេះ $\lim_{\varepsilon\to\infty}\int_0^{\varepsilon} f(x)dx = \ln 4$

**៩៣** គេអោយចំនួនគត់វិជ្ជមាន $n \geq 0$ ។

គេតាង $I_n = \int_0^1 \frac{e^{-2nx}}{e^{2x}+1}dx$ ។

ក) គណនា $I_0$ ។

ខ)ទាញរក $I_{n+1} + I_n$ ជាអនុគមន៍នៃ $n$ ។

គ) ស្រាយបញ្ជាក់ថា គ្រប់ $x \geq 0$ គេបានវិសមភាព $\frac{e^{-2(n+1)x}}{2} \leq \frac{e^{-2nx}}{e^{2x}+1} \leq \frac{e^{-2nx}}{2}$ ។

ទាញរកតម្លៃអមនៃ $I_n$ រួចកំណត់តម្លៃ $\lim_{n\to+\infty} I_n$ ។

ដំណោះស្រាយ

ក) គណនា $I_0$

គេមាន $I_n = \int_0^1 \frac{e^{-2nx}}{e^{2x}+1}dx$

បើ $n=0$ នោះ $I_0 = \int_0^1 \frac{1}{e^{2x}+1}dx = \int_0^1 \frac{e^{-2x}}{1+e^{-2x}}dx$

$$I_0 = -\frac{1}{2}\int_0^1 \frac{d(e^{-2x}+1)}{e^{-2x}+1} = -\frac{1}{2}\left[\ln(e^{-2x}+1)\right]_0^1$$

$$I_0 = -\frac{1}{2}\ln\frac{1+e^{-2}}{2} = 2\ln\frac{2e^2}{1+e^2}$$

ខ)ទាញរក $I_{n+1} + I_n$ ជាអនុគមន៍នៃ $n$

គេបាន $I_{n+1} + I_n = \int_0^1 \frac{e^{-2(n+1)x} + e^{-2nx}}{e^{2x}+1}dx$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

$$=\int_0^1 \frac{e^{-2(n+1)x}\left(e^{2x}+1\right)}{e^{2x}+1}dx$$

$$=\int_0^1 e^{-2(n+1)x}dx=\left.\frac{e^{-2(n+1)x}}{-2(n+1)}\right|_0^1$$

នាំអោយ $I_{n+1}+I_n=\frac{1}{2(n+1)}\left(\frac{e^{2(n+1)}-1}{e^{2(n+1)}}\right)$

ដូចនេះ $I_{n+1}+I_n=\frac{1}{2(n+1)}\left(\frac{e^{2(n+1)}-1}{e^{2(n+1)}}\right)$

គ) ស្រាយបញ្ជាក់ថា គ្រប់ $x\geq 0$ គេបានវិសមភាព $\frac{e^{-2(n+1)x}}{2}\leq\frac{e^{-2nx}}{e^{2x}+1}\leq\frac{e^{-2nx}}{2}$

គ្រប់ $x\geq 0$ គេបាន $e^{2x}\geq 1$ នោះ $2\leq e^{2x}+1\leq 2e^{2x}$

$\Rightarrow\frac{1}{2e^{2x}}\leq\frac{1}{e^{2x}+1}\leq\frac{1}{2}$

គ្រប់ $x\geq 0$ , $e^{-2nx}>0$ នោះ $\frac{e^{-2nx}}{2e^{2x}}\leq\frac{e^{-2nx}}{e^{2x}+1}\leq\frac{e^{-2nx}}{2}$

នោះ $\frac{e^{-2(n+1)x}}{2}\leq\frac{e^{-2nx}}{e^{2x}+1}\leq\frac{e^{-2nx}}{2}$ ពិត

ទាញរកតម្លៃអមនៃ $I_n$ រួចកំណត់តម្លៃ $\lim\limits_{n\to+\infty} I_n$

តាមសម្រាយខាងលើ គេមាន $\frac{e^{-2(n+1)x}}{2}\leq\frac{e^{-2nx}}{e^{2x}+1}\leq\frac{e^{-2nx}}{2}$

យើងបាន $\int_0^1\frac{e^{-2(n+1)x}}{2}dx\leq\int_0^1\frac{e^{-2nx}}{e^{2x}+1}dx\leq\int_0^1\frac{e^{-2nx}}{2}dx$

$$\Rightarrow -\frac{1}{4(n+1)}e^{-2(n+1)x}\Big|_0^1\leq I_n\leq -\frac{1}{2n}e^{-2nx}\Big|_0^1$$

នាំអោយ $\frac{1-e^{-2(n+1)}}{4(n+1)}\leq I_n\leq\frac{1-e^{-2n}}{4n}$

ដោយ $\lim\limits_{n\to+\infty}\frac{1-e^{-2(n+1)}}{4(n+1)}=\lim\limits_{n\to+\infty}\frac{1-e^{-2n}}{4n}=0$

ដូចនេះ $\lim\limits_{n\to+\infty} I_n=0$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

៩៤ គេអោយ $p,q$ ជាពីរចំនួនពិតផ្សេងគ្នា ។ រកតម្លៃអតិបរមានៃអនុគមន៍
$y=\sqrt{x^2-2px+2p^2}+\sqrt{x^2-2qx+2q^2}$ ។

ដំណោះស្រាយ

គេអាចសរសេរ $y=\sqrt{(x-p)^2+p^2}+\sqrt{(x-q)^2+q^2}$

យើងតាងចំណុច $M\left(x-p,|p|\right)$ និង $N\left(x-q,-|q|\right)$

គេបាន $y=OM+ON\geq MN$

សញ្ញា $(=)$ កើតមានកាលណា $M,O,N$ រត់ត្រង់គ្នា

នោះគេបាន $S_{\Delta OMN}=\frac{1}{2}\begin{vmatrix}0 & 0 & 1\\ x-p & |p| & 1\\ x-q & -|q| & 1\end{vmatrix}=0$

នាំអោយ $-|q|(x-p)-|p|(x-q)=0$

$$(|p|+|q|)x=|p|q+|q|p$$

$$x=\frac{p|q|+q|p|}{|p|+|q|}$$



$\min y = MN = \sqrt{(x-p-x+q)^2+(|p|+|q|)^2}$

ដូចនេះ $\min y = \sqrt{(p-q)^2+(|p|+|q|)^2}$

**៩៦** ក) ស្រាយបញ្ជាក់ថា $\ln x \le x-1$ ចំពោះ $x>0$ ។

ខ) តាង $t_i = \dfrac{nx_i}{x_1+x_2+\cdots+x_n}$ ដែល $x_i>0\,,(i=1,2,\cdots,n)$ ។

ដោយប្រើវិសមភាព $\ln x \le x-1$ ចូរស្រាយបញ្ជាក់ថា $\sqrt[n]{x_1.x_2\cdots x_n} \le \dfrac{x_1+x_2+\cdots+x_n}{n}$ ។

ដំណោះស្រាយ

ក) ស្រាយបញ្ជាក់ថា $\ln x \le x-1$ ចំពោះ $x>0$

តាងអនុគមន៍ $f(x)=x-1-\ln x,\ x>0$

$$f'(x)=1-\frac{1}{x}=\frac{x-1}{x}$$

$f'(x)=0$ កាលណា $x=1$

តារាងសញ្ញាដេរីវេ

| $x$ | $0$ | $1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | | $+$ |

អនុគមន៍ $f(x)$ មានអប្បបរមាត្រង់ $x=1$ ដែល $f(1)=0$

នោះ $f(x)\ge f(1)=0$

$x-1-\ln x\ge 0$

ដូចនេះ $\ln x \le x-1$

ខ) ស្រាយបញ្ជាក់ថា $\sqrt[n]{x_1.x_2\cdots x_n} \le \dfrac{x_1+x_2+\cdots+x_n}{n}$

គេមាន $x_i>0$ នោះ $t_i>0$

តាមសម្រាយខាងលើ $\ln x \le x-1$ យើងបាន

$\ln t_1 \le t_1-1$

$\ln t_2 \le t_2-1$

.....................

$\ln t_n \le t_n-1$

នាំអោយ $\ln t_1+\ln t_2+\cdots+\ln t_n \le (t_1+t_2+\cdots+t_n)-n$

$\ln(t_1.t_2\cdots t_n)\le(t_1+t_2+\cdots+t_n)-n$

នោះ $\ln\dfrac{n^n x_1.x_2\cdots x_n}{\left(x_1+x_2+\cdots+x_n\right)}\le n\dfrac{\left(x_1+x_2+\cdots+x_n\right)}{x_1+x_2+\cdots+x_n}-n=0$

$$\frac{n^n.x_1\cdot x_2\cdots x_n}{\left(x_1+x_2+\cdots+x_n\right)^n}\le 1$$

នាំអោយ $\sqrt[n]{x_1\cdot x_2\cdots x_n}\le\dfrac{x_1+x_2+\cdots+x_n}{n}$ ពិត

**៩៧** គណនាអាំងតេក្រាលខាងក្រោម

ក) $I=\displaystyle\int_{-\pi}^{\pi}\left(\frac{\sin^2 x}{3^x+1}\right)dx$ ខ) $J=\displaystyle\int_{-\pi}^{\pi}\sqrt{1-\sin x}dx$

គ) $K=\displaystyle\int_0^1\left(\arcsin x\right)^2dx$ ។

ដំណោះស្រាយ

ក) $I=\displaystyle\int_{-\pi}^{\pi}\left(\frac{\sin^2 x}{3^x+1}\right)dx$

យើងបាន $I=\displaystyle\int_{-\pi}^{0}\frac{\sin^2 x}{3^x+1}dx+\int_0^{\pi}\frac{\sin^2 x}{3^x+1}dx$

ចំពោះ $\displaystyle\int_{-\pi}^{0}\frac{\sin^2 x}{3^x+1}dx$

តាង $x=-t$ នោះ $dx=-dt$

$$\begin{cases}x=0\Rightarrow t=0\\ x=-\pi\to t=\pi\end{cases}$$

នោះ $\displaystyle\int_{-\pi}^{0}\frac{\sin^2 x}{3^x+1}dx=\int_0^{\pi}\frac{\sin^2\left(-t\right)\left(-dt\right)}{3^{-t}+1}=\int_0^{\pi}\frac{3^t\sin^2 tdt}{3^t+1}=\int_0^{\pi}\frac{3^x\sin^2 x}{3^x+1}dx$

នាំអោយ $I=\displaystyle\int_0^{\pi}\frac{3^x\sin^2 xdx}{3^x+1}+\int_0^{\pi}\frac{\sin^2 x}{3^x+1}dx$

$$I=\int_0^{\pi}\sin^2 xdx=\frac{1}{2}\int_0^{\pi}\left(1-\cos 2x\right)dx$$

$$I=\frac{1}{2}\left[x-\frac{1}{2}\sin 2x\right]_0^{\pi}=\frac{\pi}{2}$$

ដូចនេះ $I=\dfrac{\pi}{2}$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ll

ខ) $J=\int_{-\pi}^{\pi}\sqrt{1-\sin x}\,dx$

យើងបាន $J=\int_{-\pi}^{\pi}\sqrt{1-\sin x}\,dx=\int_{-\pi}^{\pi}\sqrt{1+\cos\left(\frac{\pi}{2}+x\right)}\,dx$

$J=\int_{-\pi}^{\pi}\sqrt{2}\left|\cos\left(\frac{x}{2}+\frac{\pi}{4}\right)\right|dx$

ចំពោះ $-\pi\le x\le\pi$ នោះ $-\frac{\pi}{2}\le\frac{x}{2}+\frac{\pi}{4}\le\frac{3\pi}{4}$

តាង $t=\frac{x}{2}+\frac{\pi}{4}$ នោះ $dt=\frac{dx}{2}$

$$\begin{cases}x=\pi\Rightarrow t=\frac{3\pi}{4}\\ x=-\pi\Rightarrow t=-\frac{\pi}{4}\end{cases}$$

$$J=\int_{-\frac{\pi}{4}}^{\frac{3\pi}{4}}2\sqrt{2}\left|\cos t\right|dt=\int_{-\frac{\pi}{4}}^{\frac{\pi}{2}}2\sqrt{2}\cos t\,dt-\int_{\frac{\pi}{2}}^{\frac{3\pi}{4}}2\sqrt{2}\cos t\,dt$$

$$=2\sqrt{2}\left[\sin t\right]_{-\frac{\pi}{4}}^{\frac{\pi}{2}}-2\sqrt{2}\left[\sin t\right]_{\frac{\pi}{2}}^{\frac{3\pi}{4}}$$

$$=2\sqrt{2}\left(1+\frac{\sqrt{2}}{2}\right)-2\sqrt{2}\left(\frac{\sqrt{2}}{2}-1\right)$$

$$=4\sqrt{2}$$

ដូចនេះ $J=4\sqrt{2}$

គ) $K=\int_0^1\left(\arcsin x\right)^2dx$

តាង $u=\left(\arcsin x\right)^2$ នោះ $du=2\arcsin x\cdot\frac{1}{\sqrt{1-x^2}}$

$dv=dx$ នោះ $v=x$

យើងបាន $K=x\left(\arcsin x\right)^2\Big|_0^1-\int_0^1\arcsin x\cdot\frac{2x}{\sqrt{1-x^2}}dx$

$$=\left(\frac{\pi}{2}\right)^2-\int_0^1\arcsin x\cdot\frac{2x}{\sqrt{1-x^2}}dx$$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

តាង $u=\arcsin x$ នោះ $du=\dfrac{dx}{\sqrt{1-x^2}}$

$dv=\dfrac{2xdx}{\sqrt{1-x^2}}$ នោះ $v=-2\sqrt{1-x^2}$

$$\int_0^1 \arcsin x\cdot\frac{2x}{\sqrt{1-x^2}}dx=-2\sqrt{1-x^2}.\arcsin x\Big|_0^1+2\int_0^1 dx$$

$=2x\,|_0^1=2$

ដូចនេះ $K=\dfrac{\pi^2}{4}-2$

**៩៨** $x,y,z$ ជាបីចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $xyz=1, x+\dfrac{1}{z}=5$ និង $y+\dfrac{1}{x}=29$ ។ គេយក $z+\dfrac{1}{y}=\dfrac{m}{n}$ ដែល $m$ និង $n$ ជាចំនួនគត់វិជ្ជមានបឋមរវាងគ្នា ។ គណនា $m+n$ ។

ដំណោះស្រាយ

យើងបាន $\left(x+\dfrac{1}{z}\right)\left(y+\dfrac{1}{x}\right)\left(z+\dfrac{1}{y}\right)=5\cdot 29\cdot\dfrac{m}{n}$

$$xyz+x+y+z+\frac{1}{x}+\frac{1}{y}+\frac{1}{z}+\frac{1}{xyz}=\frac{145m}{n}$$

$$1+x+y+z+(29-y)+\left(\frac{m}{n}-z\right)+(5-x)+1=\frac{145m}{n}$$

នាំអោយ $36+\dfrac{m}{n}=\dfrac{145m}{n}$

$$\frac{144m}{n}=36$$

នោះ $\dfrac{m}{n}=\dfrac{36}{144}=\dfrac{1}{4}$

ដូចនេះ $m+n=5$

**៩៩** គេអោយ $(a,b,c)$ ជាចម្លើយពិតនៃប្រព័ន្ធសមីការ $\begin{cases}x^3-xyz=2\\ y^3-xyz=6\\ z^3-xyz=20\end{cases}$ ។



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

តម្លៃធំបំផុតដែលអាចនៃ $a^3+b^3+c^3$ អាចសរសេរជាទម្រង់ $\frac{m}{n}$ ដែល $m,n$ ជាចំនួនគត់វិជ្ជមានបឋមរវាងគ្នា ។ ចូររក $m+n$ ។

ដំណោះស្រាយ

ប្រព័ន្ធសមីការ $\begin{cases} x^3-xyz=2 \\ y^3-xyz=6 \\ z^3-xyz=20 \end{cases} \quad (1)$

តាមប្រព័ន្ធសមីការ $(1)$ គេទាញបាន $a^3=c^3-18$ និង $b^3=c^3-14$

យើងបាន $20=c^3-\sqrt[3]{c^3-18}\cdot\sqrt[3]{c^3-14}c$

$$20=c^3-\sqrt[3]{\left(c^3-18\right)\left(c^3-13\right)c^3}$$

នាំអោយ $c^3\left(c^3-18\right)\left(c^3-14\right)=\left(c^3-20\right)^3$

$$c^9-32c^6+252c^3=c^9-60c^6+1200c^3-8000$$

$$28c^6-948c^3+8000=0$$

ឬ $7c^6-237c^3+2000=0$

ដោះស្រាយសមីការដឺក្រេទីពីរដែលមានអថេរ $c^3$ យើងបាន

$$c^3=\frac{237\pm\sqrt{237^2-56000}}{14}=\frac{237\pm13}{14}$$

ដើម្បីបាន $a^3+b^3+c^3$ ធំបំផុត យើងយក $c^3=\frac{237+13}{14}=\frac{125}{7}$

នោះ $a^3+b^3+c^3=\left(c^3-18\right)+\left(c^3-14\right)+c^3=3c^3-32=3\cdot\frac{125}{7}-32=\frac{151}{7}$

ដូចនេះ $m+n=158$

**១០០** $a,b,x,y$ ជាចំនួនពិតផ្ទៀងផ្ទាត់

$$ax+by=3,$$
$$ax^2+by^2=7,$$
$$ax^3+by^3=16,$$
$$ax^4+by^4=42$$

។

ចូររក $ax^5+by^5$ ។

ដំណោះស្រាយ

យើងពិនិត្យមើលដូចតទៅ

$$(ax+by)(x+y)=ax^2+by^2+xy(a+b)$$
$$(ax^2+by^2)(x+y)=ax^3+by^3+xy(ax+by)$$
$$(ax^3+by^3)(x+y)=ax^4+by^4+xy(ax^2+by^2)$$
$$(ax^4+by^4)(x+y)=ax^5+by^5+xy(ax^4+by^4)$$

បើយើងយក $C=x+y$ និង $D=xy$ ជំនួសចូលសមីការទាំងបួនខាងលើ យើងបាន

$$\begin{cases}3C=7+D(a+b)\\7C=16+3D\\16C=42+7D\\42C=ax^5+by^5+16D\end{cases}$$

តម្លៃ $ax^5+by^5$ ជាប់ទាក់ទិននឹង $C,D$

យើងដោះស្រាយបាន $C=-14$ និង $D=-38$

ដូចនេះ $ax^5+by^5=20$

**១០១** $n$ ជាចំនួនគត់វិជ្ជមាន ហើយ $d$ ជាចំនួនមានលេខមួយខ្ទង់ (គិតក្នុងប្រព័ន្ធគោល ១០) ។ រក $n$ ដោយដឹងថា $\dfrac{n}{810}=0.d25d25d25\cdots$ ។

ដំណោះស្រាយ

អង្គខាងស្តាំជាចំនួនទសភាគខួប

តាង $x=0.d25d25d25\cdots$ នោះ $d25=1000x-x=999x$

គេបាន $x=\dfrac{d25}{999}$

នាំអោយ $\dfrac{n}{810}=\dfrac{d25}{999}$

$$3^3.37.n=2.3^4.5.(d25)$$

នោះ $37n=2.3.5.(d25)$

គេសង្កេតឃើញថា $d25$ មានពីរខ្ទង់ចុងក្រោយគឺ 25 នោះ $d25$ ត្រូវតែជាពហុគុណនៃ 25

$d25$ ក៏ជាពហុគុណនៃ 37

ចំនួនតែមួយគត់ដែលអាចជាពហុគុណនៃ 25 និង 37 គឺ 925

នាំអោយ $d=9$ និង $n=750$

ដូចនេះ $n=750$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

**១០២** គេអោយ $n$ ជាចំនួនគត់វិជ្ជមាន ។ តាង $p(n)$ ជាផលគុណខ្ទង់ដែលមិនសូន្យនៃ $n$ ។ ( បើ $n$ មានតែមួយខ្ទង់ នោះ $p(n)$ ស្មើនឹងខ្ទង់នោះ ) ។ គេតាង

$S = p(1) + p(2) + \cdots + p(999)$ ។ រកកត្តាបឋមធំបំផុតនៃ $S$ ។

យើងយក $T = p(1) + p(2) + p(3) + \cdots + p(99)$

$$p(1) + p(2) + \cdots + p(9) = 1 + 2 + 3 + \cdots + 9 = 45$$

ហើយ $p(10) + p(11) + \cdots + p(19) = 46$

$$p(20) + p(21) + \cdots + p(29) = 2.46$$

$$p(30) + p(31) + \cdots + p(39) = 3.46$$

.....................................................

$$p(90) + p(91) + \cdots + p(99) = 9.46$$

នោះ $T = 45 + 46(1 + 2 + 3 + \cdots + 9) = 45 + 46.45 = 45.47$

យើងបាន $T = p(1) + p(2) + \cdots + p(99)$

$$T = p(101) + p(102) + \cdots + p(199)$$

$$2T = p(201) + p(202) + \cdots + p(299)$$

.......................................................

$$9T = p(901) + p(902) + \cdots + p(999)$$

នាំអោយ $S = p(100) + p(200) + \cdots + p(900) + T + 2T + \cdots + 9T$

$$S = (1 + 2 + 3 + \cdots + 9) + T(1 + 2 + 3 + \cdots + 9)$$

$$S = 45 + 46T$$

$$S = 45 + 46.45.47$$

នោះ $S = 45.2163 = 45.21.103$

ដូចនេះ 103ជាកត្តាបឋមធំបំផុតនៃ $S$

**១០៣** ស៊ីតធរណីមាត្រអនន្តតួមួយមានផលបូកតួស្មើ 2005 ។ ស៊ីតធរណីមាត្រអនន្តតួថ្មីមួយត្រូវបានបង្កើតដោយយកតួនៃស៊ីតមុនលើកជាការេ ហើយផលបូកតួថ្មីស្មើ 10 ដងនៃផលបូកស៊ីតដើម។ ផលធៀបរួមនៃស៊ីតដើមអាចសរសេរជាទម្រង់ $\frac{m}{n}$ ដែល $m, n$ ជាចំនួនគត់វិជ្ជមានបឋមរវាងគ្នា ។ ចូររក $m + n$ ។

ដំណោះស្រាយ

តាង $a$ ជាតួដំបូងនៃស៊ីតដើម ហើយ $r$ ជាផលធៀបរួមដែល $|r| < 1$

ផលបូកតួនៃស៊ីតដើម $\frac{a}{1-r} = 2005 \quad (1)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

ផលបូកតួនៃស្វ៊ីតថ្មី $\dfrac{a^2}{1-r^2}=20050 \quad (2)$

តាម $(1)$ និង $(2)$ យើងបានសមីការ $\dfrac{2005^2(1-r)^2}{1-r^2}=20050$

នាំអោយ $2005(1-r)^2=10(1-r^2)=10(1-r)(1+r)$

$$2005(1-r)=10(1+r)$$

$$2015r=1995$$

$$r=\frac{1995}{2015}=\frac{399}{403}$$

ដោយ $\gcd(399,403)=1$ នោះ $m=399,\ n=403$

ដូចនេះ $m+n=802$

**១០៨** រកចំនួនគត់ដែលនៅជិត $1000\sum_{n=3}^{10000}\dfrac{1}{n^2-4}$ បំផុត ។

ដំណោះស្រាយ

យើងមាន $\dfrac{1}{n^2-4}=\dfrac{A}{n-2}+\dfrac{B}{n+2}$ ដែល $n\geq 3$

$$A(n+2)+B(n-1)=1$$

$$(A+B)n+(2A-2B)=1$$

នោះ $\begin{cases}A+B=0\\2A-2B=1\end{cases}$

នាំអោយ $A=\dfrac{1}{4},B=-\dfrac{1}{4}$

យើងបាន $1000\sum_{n=3}^{10000}\dfrac{1}{n^2-4}=1000\times\dfrac{1}{4}\sum_{n=3}^{10000}\left(\dfrac{1}{n-2}-\dfrac{1}{n+2}\right)$

$$=250\left(\sum_{n=3}^{10000}\frac{1}{n-2}-\sum_{n=3}^{10000}\frac{1}{n+2}\right)$$

$$=250\left(1+\frac{1}{2}+\frac{1}{3}+\cdots+\frac{1}{9998}-\frac{1}{5}-\frac{1}{6}-\frac{1}{7}\cdots-\frac{1}{10002}\right)$$

$$=250\left(1+\frac{1}{2}+\frac{1}{3}+\frac{1}{4}-\frac{1}{9999}-\frac{1}{10000}-\frac{1}{10001}-\frac{1}{10002}\right)$$

$$= 250\left(\frac{25}{12} - \frac{1}{9999} - \frac{1}{10000} - \frac{1}{10001} - \frac{1}{10002}\right)$$

$$= 520.\overline{83} - 250\left(\frac{1}{9999} + \frac{1}{10000} + \frac{1}{10001} + \frac{1}{10002}\right)$$

ដោយហេតុថា $250\left(\frac{1}{9999} + \frac{1}{10000} + \frac{1}{10001} + \frac{1}{10002}\right) < \frac{1}{10}$

នោះ $1000\sum_{n=3}^{10000}\frac{1}{n^2-4} > 250.5$

ដូចនេះ 251 ជាចំនួនគត់ដែលនៅជិត $1000\sum_{n=3}^{10000}\frac{1}{n^2-4}$ បំផុត

**១០៥** បើគេបន្ថែម $k$ ទៅលើចំនួន 36,300,596 គេនិងទទួលបានចំនួនថ្មីចំនួនបីដែលជាការេនៃបីតួបន្ត គ្នានៃស្វ៊ីតនព្វន្តមួយ ។ រកតម្លៃ $k$ ។

ដំណោះស្រាយ

តាមសម្មតិកម្ម យើងអាចសរសេរបានថា $\begin{cases} 36+k=a^2 & (1) \\ 300+k=(a+d)^2 & (2) \\ 596+k=(a+2d)^2 & (3) \end{cases}$

យក $(2)-(1): 2ad+d^2=264$

យក $(3)-(1): 4ad+4d^2=560$

នាំអោយ $2d^2=32$

នោះ $d=\pm 4$ និង $a=\pm 31$

គេបាន $36+k=a^2=961$

ដូចនេះ $k=925$

**១០៦** $m$ ជាចំនួនគត់វិជ្ជមាន ។ $a_0,a_1,\cdots,a_m$ ជាស្វ៊ីតនៃចំនួនពិតដែល $a_0=37, a_1=72$ $, a_m=0$ និង $a_{k+1}=a_{k-1}-\frac{3}{a_k}$ ចំពោះ $k=1,2,\cdots,m-1$ ។ ចូររក $m$ ។

ដំណោះស្រាយ

យើងមាន $a_m=0$ នោះ $a_{m-2}=\frac{3}{a_{m-1}}$

នាំអោយ $a_{m-1}a_{m-2}=3 \ (1)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

ហើយ $a_{m-1}=a_{m-3}-\dfrac{3}{a_{m-2}}$ នោះ $a_{m-1}a_{m-2}=a_{m-2}a_{m-3}-3 \quad (2)$

តាម $(1)$ និង $(2)$: $a_{m-2}a_{m-3}=6 \quad (3)$

ហើយ $a_{m-2}=a_{m-4}-\dfrac{3}{a_{m-3}}$ នោះ $a_{m-2}a_{m-3}=a_{m-3}a_{m-4}-3 \quad (4)$

តាម $(3)$ និង $(4)$: $a_{m-3}a_{m-4}=9$

យើងអាចទាញសន្និដ្ឋានថា $a_{m-k}a_{m-k-1}=3k$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $k$

យើងយក $k=m-1$ នោះ $a_1a_0=3(m-1)$

នាំអោយ $3(m-1)=37.72$

ដូចនេះ $m=888$

**១០៧** គេអោយ $(1+\sin t)(1+\cos t)=\dfrac{5}{4}$ និង $(1-\sin t)(1-\cos t)=\dfrac{m}{n}-\sqrt{k}$ ដែល $k,m$ និង $n$ ជាចំនួនគត់វិជ្ជមាន ហើយ $m,n$ បឋមរវាងគ្នា ។ ចូររក $k+m+n$ ។

ដំណោះស្រាយ

តាង $\alpha=\dfrac{m}{n}-\sqrt{k}$

យើងមាន $(1+\sin t)(1+\cos t)=\dfrac{5}{4}$

$$1+\sin t+\cos t+\sin t\cos t=\frac{5}{4}$$

$$(1-\sin t)(1-\cos t)=\alpha$$

$$1-\sin t-\cos t+\sin t\cos t=\alpha$$

នាំអោយ $2+2\sin t\cos t=\dfrac{5}{4}+\alpha \quad (1)$

ម្យ៉ាងទៀត $(1+\sin t)(1+\cos t)(1-\sin t)(1-\cos t)=\dfrac{5}{4}\alpha$

$$(1-\sin^2 t)(1-\cos^2 t)=\frac{5}{4}\alpha$$

$$\cos^2 t\sin^2 t=\frac{5}{4}\alpha$$

នោះ $\sin t\cos t=\dfrac{\sqrt{5\alpha}}{2} \quad (2)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

តាម $(1)$ និង $(2)$ យើងបាន $2+\sqrt{5\alpha}=\dfrac{5}{4}+\alpha$

ឬ $5\alpha=\left(\alpha-\dfrac{3}{4}\right)^2$

$$\alpha^2-\frac{13}{2}\alpha+\frac{9}{16}=0$$

យើងទាញបាន $\alpha=\dfrac{13}{4}-\sqrt{10}$

នាំអោយ $m=13, n=4, k=10$

ដូចនេះ $k+m+n=27$

**១០៨** គេអោយ $x=\dfrac{\sum_{n=1}^{44}\cos n^0}{\sum_{n=1}^{44}\sin n^0}$ ។ រកចំនួនគត់ធំបំផុតដែលមិនធំជាង $100x$ ។

ដំណោះស្រាយ

យើងមាន $x=\dfrac{\sum_{n=1}^{44}\cos n^0}{\sum_{n=1}^{44}\sin n^0}=\dfrac{\sum_{n=46}^{89}\sin n^0}{\sum_{n=1}^{44}\sin n^0}=\dfrac{\sum_{n=1}^{44}\sin(n+45)^0}{\sum_{n=1}^{44}\sin n^0}$

តែ $\sin(n+45)^0=\dfrac{\sqrt{2}}{2}\left(\sin n^0+\cos n^0\right)$

$$\Rightarrow x=\frac{\frac{\sqrt{2}}{2}\sum_{n=1}^{44}\left(\sin n^0+\cos n^0\right)}{\sum_{n=1}^{44}\sin n^0}=\frac{\frac{\sqrt{2}}{2}\left(\sum_{n=1}^{44}\sin n^0+\sum_{n=1}^{44}\cos n^0\right)}{\sum_{n=1}^{44}\sin n^0}=\frac{\sqrt{2}}{2}(1+x)$$

នោះ $\sqrt{2}x=1+x$

នាំអោយ $x=\dfrac{1}{\sqrt{2}-1}=\sqrt{2}+1\approx 2.414$

នោះ $100x\approx 241.4$

ដូចនេះ ចំនួនគត់ដែលមិនធំជាង $100x$ គឺ $241$

**១០៩** ជាចំនួនកុំផ្លិចមួយដែលមានផ្នែកនិម្មិត 164 ហើយ $n$ ជាចំនួនគត់វិជ្ជមានមួយដែល

$\frac{z}{z+n}=4i$ ។ ចូររក $n$ ។

ដំណោះស្រាយ

តាង $z=a+164i$ ដែល $a$ ជាចំនួនពិត

យើងបាន $a+164i=z$

$$a+164i=4i(z+n)$$

$$a+164i=4i(a+n+164i)$$

$$a+164i=-656+4i(a+n)$$

គេទាញបាន $a=-656$ និង $164=4(a+n)$

ដូចនេះ $n=697$

**១១០** គេអោយ $P_0(x)=x^3+313x^2-77x-8$ ។ ចំពោះចំនួនគត់ $n\geq 1$ គេកំណត់ $P_n(x)=P_{n-1}(x-n)$ ។ រកមេគុណនៃ $x$ នៅក្នុង $P_{20}(x)$ ។

ដំណោះស្រាយ

យើងមាន $P_n(x)=P_{n-1}(x-n)$

$$P_{20}(x)=P_{19}(x-20)$$
$$=P_{18}((x-20)-19)$$
$$=P_{17}((x-20)-19-18)$$
$$\vdots$$
$$=P_0(x-(20+19+18+\cdots+2+1))$$
$$=(x-210)^3+313(x-210)^2-77(x-210)-8$$

ដើម្បីរកមេគុណនៃ $x$ យើងប្រើទ្វេធាញូតុន

មេគុណនៃ $x$ នៅក្នុងពន្លាត $(x-210)^3$ គឺ $3(-210)^2$

មេគុណនៃ $x$ នៅក្នុងពន្លាត $(x-210)^2$ គឺ $-2.201$

មេគុណនៃ $x$ នៅក្នុង $P_{20}(x)$ គឺ $3(-210)^2-2.313.210-77=763$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

១១១ តាង $P$ ជាផលគុណនៃរឹសមិនពិតនៃសមីការ $x^4-4x^3+6x^2-4x=2005$ ។
ចូរកំណត់ $\lfloor P \rfloor$។
សំគាល់ $\lfloor P \rfloor$ តាងអោយចំនួនគត់ធំបំផុតដែលតូចជាងឬស្មើ $P$ ។
ដំណោះស្រាយ
មេគុណនៃពហុធា $p(x)=x^4-4x^3+6x^2-4x$ គឺ $1,-4,6,-4$
ចំនួនទាំងនេះជាមេគុណទ្វេធា $\pm\binom{4}{k}$ ចំពោះ $k=0,1,2,3$
យើងបាន $p(x)+1=x^4-4x^3+6x^2-4x+1=(x-1)^4$
រឹសមិនពិតដែលត្រូវរក ជារឹសនៃសមីការ $(x-1)^4=2006$
យើងតាង $y=x-1$ នោះ $y^4=2006$
$y$ ទាំងបួនដែលផ្ទៀងផ្ទាត់សមីការគឺ $y=\pm\sqrt[4]{2006}\pm i\sqrt[4]{2006}$
នាំអោយ $x=1\pm\sqrt[4]{2006}$ និង $x=1\pm i\sqrt[4]{2006}$
យើងបាន $P=\left(1+i\sqrt[4]{2006}\right)\left(1-i\sqrt[4]{2006}\right)=1+\sqrt{2006}$
ដោយ $40=\sqrt{1600}<\sqrt{2006}<\sqrt{2500}=50$
នោះ $44=\sqrt{1936}<\sqrt{2006}<\sqrt{2025}=45$
$45<1+\sqrt{2006}<46$
ដូចនេះ $\lfloor P \rfloor=45$

១១២ គេអោយ $P(z)=z^3+az^2+bz+c$ ដែល $a,b,c$ ជាចំនួនពិត ។ $\omega$ ជាចំនួនកុំផ្លិចមួយដែលធ្វើអោយរឹសទាំងបីនៃ $P(z)$ មានតម្លៃ $\omega+3i,\omega+9i$ និង $2\omega-4$ ដែល $i^2=-1$ ។ ចូររក $|a+b+c|$ ។
ដំណោះស្រាយ
តាង $\omega=u+vi$ ដែល $u,v$ ជាចំនួនពិត
យើងបាន $a=-\left[(\omega+3i)+(\omega+9i)+(2\omega-4)\right]=4-12i-4\omega \quad (1)$

$$b=(\omega+3i)(\omega+9i)+(\omega+9i)(2\omega-4)+(2\omega-4)(\omega+3i)$$
$$=5\omega^2-8\omega+36\omega i-48i-27 \ (2)$$

តាម $(1): v=-3$
យក $\omega=u-3i$ ជំនួសចូល $(2)$ យើងបាន

$$b=5(u-3i)^2-8(u-3i)+36(u-3i)i-48i-27$$

ដោយ $b$ ជាចំនួនពិតនោះ $6u-24=0$
នោះ $u=4$
គេបាន $w=4-3i$
រឹសទាំងបីនៃ $P(z)$ រួមមាន $r_1=4, r_2=4+6i$ និង $r_3=4-6i$

$$a=-(r_1+r_2+r_3)=-12$$
$$b=r_1r_2+r_2r_3+r_3r_1=84$$
$$c=-(r_1r_2r_3)=-208$$

ដូចនេះ $|a+b+c|=136$

**១១៣** រកគ្រប់ចំនួនពិត $x, y$ និង $z$ ដែលផ្ទៀងផ្ទាត់ $(x+1)yz=12, (y+1)zx=4$ និង $(z+1)xy=4$ ។
ដំណោះស្រាយ
យើងមាន $(x+1)yz=12\ (1)$

$$(y+1)zx=4\ (2)$$
$$(z+1)xy=4\ (3)$$

យើងបាន $xz+xyz=xy+xyz=4$

$$x(y-z)=0$$

បើ $x=0$ នោះតាម $(2)$ $0=4$ មិនពិត
បើ $y=z$ នោះតាម $(1):(x+1)z^2=12$ និង $(z+1)zx=4$
នាំអោយ $z^3+z^2-8z-12=0$

$$(z-3)(z+2)^2=0$$

ដូចនេះ $(x,y,z)=\left(\frac{1}{3},3,3\right)$ និង $(x,y,z)=(2,-2,-2)$

**១១៤** ត្រីកោណ $ABC$ ស្ថិតនៅក្នុងប្លង់កាតេស្យង់ មានក្រឡាផ្ទៃ 70 ។ កូអរដោនេចំណុច $B(12,19)$ និងចំណុច $C(23,20)$ ហើយចំណុច $A(p,q)$ ។ បន្ទាត់មួយត្រួតលើមេដ្យាននៃជ្រុង $BC$ មានមេគុណប្រាប់ទិសស្មើ $-5$ ។ រកតម្លៃធំបំផុតដែលអាចនៃ $p+q$ ។
ដំណោះស្រាយ
ចំណុចកណ្ដាល $BC$ គឺ $I\left(\frac{35}{2},\frac{39}{2}\right)$
តាង $(l)$ ជាបន្ទាត់ដែលកាត់តាមចំណុច $I$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

សមីការបន្ទាត់ $(l): y-\frac{39}{2}=-5\left(x-\frac{35}{2}\right)$

$y=-5x+107$

គេបានកូអរដោនេចំណុច $A(p,q)=A(p,-5p+107)$




យើងបង្កើតត្រីកោណថ្មីដោយរំកិលកំពូល $B$ មកនៅចំគល់តម្រុយ

ត្រីកោណថ្មី $A'B'C'$ មានកំពូល $A'(p-12,-5p+88), B'(0,0)$ និង $C'(11,1)$

$S_{\Delta A'B'C'} = S_{\Delta ABC} = \frac{1}{2}\left|p-12-11(-5p+88)\right| = \frac{1}{2}\left|56p-980\right|$

នាំអោយ $\frac{1}{2}\left|56p-980\right|=70$

នោះ $56p-980=\pm 140$

បើ $p=20$ នោះ $p+q=-4\times 20+107=27$

បើ $p=15$ នោះ $p+q=-4\times 15+107=47$

ដូចនេះ តម្លៃធំបំផុតដែលអាច $p+q=47$

**១១៥** រង្វង់ចារឹកក្នុងត្រីកោណ $ABC$ ប៉ះជ្រុង $AB$ ត្រង់ $P$ និងមានកាំស្មើ $21$ ។ គេអោយ $AP=23$ និង $PB=27$ ។ រកបរិមាត្រនៃត្រីកោណ $ABC$ ។

ដំណោះស្រាយ

តាង $O$ ជាផ្ចិតរង្វង់ចារឹកក្នុង

$Q$ និង $R$ ជាចំណុចប៉ះរវាងរង្វង់នឹងជ្រុង $AC,BC$ រៀងគ្នា




តាង $x=CQ$

$AP=AQ=23$ (បន្ទាត់ប៉ះគូសចេញពីចំណុច $A$ តែមួយ)

$BP=BR=27$ (បន្ទាត់ប៉ះគូសចេញពីចំណុច $B$ តែមួយ)

$CQ=CR=x$ (បន្ទាត់ប៉ះគូសចេញពីចំណុច $C$ តែមួយ)

បរិមាត្រត្រីកោណ $ABC$ គឺ $2p=2.(23+27+x)=100+2x$

តាមរូបមន្តហេរ៉ុង

$$S_{\Delta ABC}=\sqrt{p(p-x-23)(p-x-27)(p-23-27)}=\sqrt{(50+x)(27)(23)x}\ (1)$$

ម្យ៉ាងទៀត $S_{\Delta ABC}=S_{\Delta AOC}+S_{\Delta BOC}+S_{\Delta AOB}$

$$=\frac{1}{2}(21)\left[(23+x)+(27+x)+(23+27)\right]=21.(50+x)\ (2)$$

តាម $(1)$ និង $(2)$ យើងបាន $\sqrt{(50+x)(27)(23)x}=21(50+x)$

នាំអោយ $x=\frac{245}{2}$

ដូចនេះ បរិមាត្រ $2p=100+245=345$

**១១៦** គេអោយស៊ីត $\{a_n\}$ កំណត់ដោយ $a_1 = a_2 = 1$ និង $a_n = 7a_{n-1} - a_{n-2}, n \geq 3$ ។ ស្រាយបញ្ជាក់ថា $a_n + a_{n+1} + 2$ ជាការេប្រាកដចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

ដំណោះស្រាយ

សមីការសំគាល់ $\lambda^2 - 7\lambda + 1 = 0$ មានរឹស $\lambda_1 = \frac{7+\sqrt{45}}{2} = \left(\frac{3+\sqrt{5}}{2}\right)^2$ និង

$$\lambda_2 = \frac{7-\sqrt{45}}{2} = \left(\frac{3-\sqrt{5}}{2}\right)^2$$

យើងបាន $a_n = C_1\lambda_1^n + C_2\lambda_2^n$

បើ $n = 1 \Rightarrow 1 = C_1\lambda_1 + C_2\lambda_2$

បើ $n = 2 \Rightarrow 1 = C_1\lambda_1^2 + C_2\lambda_2^2$

$$a_n + a_{n+1} + 2 = \lambda_1^{n-1}C_1\left(\lambda_1 + \lambda_1^2\right) + \lambda_2^{n-1}C_2\left(\lambda_2 + \lambda_2^2\right) + 2$$

$$= \lambda_1^{n-1} + \lambda_2^{n-1} + 2$$

$$= \left(\left(\frac{3+\sqrt{5}}{2}\right)^2\right)^{n-1} + \left(\left(\frac{3-\sqrt{5}}{2}\right)^2\right)^{n-1} + 2$$

$$= \left[\left(\frac{3+\sqrt{5}}{2}\right)^{n-1} + \left(\frac{3-\sqrt{5}}{2}\right)^{n-1}\right]^2 = x_n^2$$

ដែល $x_n = \left(\frac{3+\sqrt{5}}{2}\right)^{n-1} + \left(\frac{3-\sqrt{5}}{2}\right)^{n-1}$ ជាចម្លើយនៃស៊ីត $\{x_n\}$ នៃចំនួនគត់

$x_1 = 2, x_2 = 3, x_n = 3x_{n-1} - x_{n-2}, n \geq 3$

ដូចនេះ $a_n + a_{n+1} + 2$ ជាការេប្រាកដចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

**១១៧** តាង $I$ ជាផ្ចិតរង្វង់ចារិកក្នុងត្រីកោណ $ABC$ ។ រង្វង់ផ្ចិត $I$ ប៉ះជ្រុង $AB, BC$ និង $AC$ រៀងគ្នាត្រង់ចំណុច $D, E$ និង $F$ រៀងគ្នា ។ បន្ទាត់ $EF$ ប្រសព្វជាមួយបន្ទាត់ $AI, BI$ និង $DI$ រៀងគ្នាត្រង់ចំណុច $M, N$ និង $K$ ។ ស្រាយបញ្ជាក់ថា $DM.KE = DN.KF$ ។

ដំណោះស្រាយ

ចំណុច $I, D, E$ និង $B$ នៅលើរង្វង់តែមួយ

$\angle AID = 90^0 - \angle IAD$

$\angle MED = \angle FDA = 90^0 - \angle IAD$

នោះ $\angle AID = \angle MED$ ហើយចំណុច $I, D, E$ និង $M$ នៅលើរង្វង់តែមួយ



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

នាំអោយប្រាំចំណុច $I,D,B,E$ និង $M$ នៅលើរង្វង់តែមួយ និង $\angle IMB=\angle IEB=90^0$
នោះ $AM\perp BM$




ដូចគ្នាដែរ $I,D,A,N$ និង $F$ នៅលើរង្វង់តែមួយហើយ $BN\perp AN$
យក $G$ ជាចំណុចប្រសព្វរវាង $AN$ និង $BM$
$I$ ជាអរតូសង់នៃ $\Delta GAB$ ហើយ $ID\perp AB$នោះចំណុច $G,I$ និង $D$ កូលីនេអ៊ែរគ្នា
ដោយចំណុច $G,N,D$ និង $B$ នៅលើរង្វង់តែមួយ នោះ $\angle ADN=\angle G$
ដូចគ្នាដែរ $\angle BDM=\angle G$ នោះ $DK$ ពុះមុំ $\angle MDN$

តាមទ្រឹស្តីកន្លះបន្ទាត់ពុះមុំ $\frac{DM}{DN}=\frac{KM}{KN}\quad(1)$

ចំណុច $I,D,E$ និង $M$ នៅលើរង្វង់តែមួយ ហើយ $I,D,N$ និង $F$ នៅលើរង្វង់តែមួយ
គេបាន $KM.KE=KI.KD=KF.KN$

នាំអោយ $\frac{KM}{KN}=\frac{KF}{KE}\quad(2)$

តាម $(1)$ និង $(2)$: $\frac{DM}{DN}=\frac{KF}{KE}$

នោះ $DM.KE=DN.KF$ ពិត



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

**១១៨** គេអោយ $x,y,z$ ជាចំនួនគត់វិជ្ជមានដែលផ្ទៀងផ្ទាត់ $\frac{1}{x}-\frac{1}{y}=\frac{1}{z}$ ។ តាង $h$ ជាតួចែករួមធំបំផុត នៃ $x,y,z$ ។ ស្រាយបញ្ជាក់ថា $hxyz$ និង $h(y-x)$ ជាការេប្រាកដ ។

ដំណោះស្រាយ

តាង $x=ha, y=hb, z=hc$ ដែល $a,b,c$ ជាចំនួនគត់វិជ្ជមានហើយ $\gcd(a,b,c)=1$

យក $\gcd(a,b)=g$ នោះ $a=ga', b=gb'$ ដែល $a',b'$ ជាចំនួនគត់វិជ្ជមានដែល

$\gcd(a',b')=\gcd(a'-b',b')=\gcd(a',a'-b')=1$

យើងបាន $\frac{1}{a}-\frac{1}{b}=\frac{1}{c}$

$$c(b-a)=ab$$

$$c(b'-a')=a'b'g$$

គេទាញបាន $g\mid c$ និង $\gcd(a,b,c)=g=1$

ដោយ $\gcd(a,b)=1$ និង $\gcd(b-a,ab)=1$

នោះ $b-a=1$ និង $c=ab$

យើងបាន $hxyz=h^4abc=\left(h^2ab\right)^2$ និង $h(y-x)=h^2$

ដូចនេះ $hxyz$ និង $h(y-x)$ ជាការេប្រាកដ

**១១៩** គេតាង $\lfloor x\rfloor$ តាងអោយផ្នែកគត់នៃ $x$ និង $\{x\}$ ជាផ្នែកទសភាគនៃ $x$ ។ ឧទាហរណ៍ $\lfloor 2.1\rfloor=1$ និង $\{x\}=0.1$ ។

សំគាល់ ៖ $0\le\{x\}<1$ , $x-1<\lfloor x\rfloor\le x$ និង $\lfloor x\rfloor\le x<\lfloor x\rfloor+1$ ។

ចូរស្រាយបញ្ជាក់លក្ខណៈខាងក្រោម

ក) $\lfloor x+n\rfloor=\lfloor x\rfloor+n$ , $\forall x\in R, \forall n\in Z$

ខ) $\lfloor x\rfloor+\lfloor y\rfloor\le\lfloor x+y\rfloor\le\lfloor x\rfloor+\lfloor y\rfloor+1$

គ) $\lfloor x\rfloor+\lfloor -x\rfloor=\begin{cases}0 , x\in Z\\ -1, x\notin Z\end{cases}$

ឃ) $\left\lfloor\frac{\lfloor x\rfloor}{n}\right\rfloor=\left\lfloor\frac{x}{n}\right\rfloor, \forall x\in R,\forall n\in Z$

ង) $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor 2x\rfloor-\lfloor x\rfloor, x\in R$

ច) $\lfloor 2x\rfloor+\lfloor 2y\rfloor\ge\lfloor x\rfloor+\lfloor y\rfloor+\lfloor x+y\rfloor ,\forall x,y\ge 0$

ដំណោះស្រាយ



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥

ក) $\lfloor x+n \rfloor = \lfloor x \rfloor + n$ , $\forall x \in R, \forall n \in Z$

តាង $\lfloor x \rfloor = a$ នោះ $x = a + t$ ដែល $0 \le t < 1$ និង $a \in Z$

$\lfloor x \rfloor + n = a + n$ $(1)$

$x + n = a + t + n = (a+n) + t$

នាំអោយ $\lfloor x+n \rfloor = \lfloor (a+n)+t \rfloor = a + n$ $(2)$

តាម $(1)$ និង $(2)$: $\lfloor x+n \rfloor = \lfloor x \rfloor + n$ , $\forall x \in R, \forall n \in Z$

ខ) $\lfloor x \rfloor + \lfloor y \rfloor \le \lfloor x+y \rfloor \le \lfloor x \rfloor + \lfloor y \rfloor + 1$

គេមាន $\lfloor x+y \rfloor = \lfloor \lfloor x \rfloor + \{x\} + \lfloor y \rfloor + \{y\} \rfloor$

$= \lfloor \lfloor x \rfloor + \lfloor y \rfloor + \{x\} + \{y\} \rfloor$

ដោយ $o \le \{x\} < 1, 0 \le \{y\} < 1$ នោះ $0 \le \{x\} + \{y\} < 2$

នាំអោយ $\lfloor x+y \rfloor \le \lfloor x \rfloor + \lfloor y \rfloor + 1$ $(1)$

តាង $f(x) = \lfloor x \rfloor$ ជាអនុគមន៍មិនចុះ និង $\lfloor y \rfloor \le y < \lfloor y \rfloor + 1$

យើងបាន $\lfloor x \rfloor + \lfloor y \rfloor = \lfloor x + \lfloor y \rfloor \rfloor \le \lfloor x+y \rfloor \le \lfloor x + (\lfloor y \rfloor) + 1 \rfloor = \lfloor x \rfloor + \lfloor y \rfloor + 1$ $(2)$

តាម $(1)$ និង $(2)$ $\lfloor x \rfloor + \lfloor y \rfloor \le \lfloor x+y \rfloor \le \lfloor x \rfloor + \lfloor y \rfloor + 1$

គ) $\lfloor x \rfloor + \lfloor -x \rfloor = \begin{cases} 0 , x \in Z \\ -1, x \notin Z \end{cases}$

- បើ $x = m \in Z$ គេបាន $\lfloor x \rfloor = \lfloor m \rfloor = m, \lfloor -x \rfloor = \lfloor -m \rfloor = -m$

នាំអោយ $\lfloor x \rfloor + \lfloor -x \rfloor = 0$

- បើ $x \notin Z$ គេបាន $x = m + h$ ដែល $0 \le h < 1$

  $-x = -m - 1 + (1-h)$ ដែល $0 \le 1 - h < 1$

$\lfloor x \rfloor = \lfloor m+h \rfloor = m$ , $\lfloor -x \rfloor = \lfloor -m-1+(1-h) \rfloor = -m-1$

នោះ $\lfloor x \rfloor + \lfloor -x \rfloor = -1$

ដូចនេះ $\lfloor x \rfloor + \lfloor -x \rfloor = \begin{cases} 0 , x \in Z \\ -1, x \notin Z \end{cases}$

ឃ) $\left\lfloor \frac{\lfloor x \rfloor}{n} \right\rfloor = \left\lfloor \frac{x}{n} \right\rfloor$, $\forall x \in R, \forall n \in Z$

តាង $\left\lfloor \frac{x}{n} \right\rfloor = m$ នោះ $m \le \frac{x}{n} < m + 1$

$\Rightarrow mn \le x < (m+1)n$

$\Rightarrow mn \le \lfloor x \rfloor < (m+1)n$ $(m, n \in Z)$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ll

គេបាន $m\le\frac{\lfloor x\rfloor}{n}<m+1$ នោះ $\left\lfloor\frac{\lfloor x\rfloor}{n}\right\rfloor=m \ (1)$

ម្យ៉ាងទៀត $x=\lfloor x\rfloor+\{x\}$ ដែល $0\le\{x\}<1$

ហើយ $\lfloor x\rfloor=mn+r$ ដែល $0\le r<n-1$

គេបាន $\left\lfloor\frac{x}{n}\right\rfloor=m+\left\lfloor\frac{r+\{x\}}{n}\right\rfloor=m\,(2)$

តាម $(1)$ និង $(2)$ យើងបាន $\left\lfloor\frac{\lfloor x\rfloor}{n}\right\rfloor=\left\lfloor\frac{x}{n}\right\rfloor, \forall x\in R,\forall n\in Z$

ង) $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor 2x\rfloor-\lfloor x\rfloor, x\in R$

ករណីទី ១ $\{x\}<\frac{1}{2}$ នោះ $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor x\rfloor,\lfloor 2x\rfloor=2\lfloor x\rfloor$

នាំអោយ $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor 2x\rfloor-\lfloor x\rfloor$ ពិត

ករណីទី ២ $\{x\}\ge\frac{1}{2}$ នោះ $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor x\rfloor+1,\lfloor 2x\rfloor=2\lfloor x\rfloor+1$

នាំអោយ $\left\lfloor x+\frac{1}{2}\right\rfloor=\lfloor 2x\rfloor-\lfloor x\rfloor$ ពិត

ច) $\lfloor 2x\rfloor+\lfloor 2y\rfloor\ge\lfloor x\rfloor+\lfloor y\rfloor+\lfloor x+y\rfloor, \forall x,y\ge 0$

តាង $\alpha$ និង $\beta$ ជាផ្នែកទសភាគនៃ $x$ និង $y$

នោះ $x=\lfloor x\rfloor+\alpha,\ y=\lfloor y\rfloor+\beta$

ករណីទី ១ $\alpha+\beta<1$ នោះ $\lfloor x+y\rfloor=\lfloor x\rfloor+\lfloor y\rfloor$ និង $\lfloor 2x\rfloor=2\lfloor x\rfloor, \lfloor 2y\rfloor=2\lfloor y\rfloor$

នាំអោយ $2\lfloor x\rfloor+2\lfloor y\rfloor\ge 2\lfloor x\rfloor+2\lfloor y\rfloor$ ពិត

ករណីទី ២ $1\le\alpha+\beta<2$ នោះ $\lfloor x+y\rfloor=\lfloor x\rfloor+\lfloor y\rfloor+1$

ដោយ $2\le 2\alpha+2\beta$ នោះក្នុងចំណោម $2\alpha,2\beta$ មានមួយធំជាង $1$

កំណត់យក $2\alpha\ge 1$ នោះ $\lfloor 2\alpha\rfloor=2\lfloor\alpha\rfloor+1$ ហើយ $\lfloor 2y\rfloor=2\lfloor y\rfloor$

នាំអោយ $\lfloor 2x\rfloor+\lfloor 2y\rfloor\ge\lfloor x\rfloor+\lfloor y\rfloor+\lfloor x+y\rfloor, \forall x,y\ge 0$ ពិត

**ចំណេះដឹងបន្ថែម**

ចំពោះចំនួនពិត $x$ មានចំនួនគត់ $n$ មួយដែល $n\le x<n+1$

$n$ ហៅថាផ្នែកគត់នៃ $x$ ឬ floor function ដែលកំណត់សរសេរ $\lfloor x\rfloor=n$

ផលសង $x-\lfloor x\rfloor$ ហៅថាផ្នែកទសភាគនៃ $x$ ដែលកំណត់ដោយ $\{x\}=x-\lfloor x\rfloor$

ចំនួនគត់ $\lfloor x \rfloor + 1$ ហៅថា Ceiling function ដែលតំណាងដោយ $\lceil x \rceil$

ឧទាហរណ៍ $\lfloor -3.9 \rfloor = -4, \{-3.9\} = .1$ និង $\lceil -3.9 \rceil = -3$

លក្ខណៈ

ក) បើ $a$ និង $b$ ជាចំនួនគត់ ហើយ $b > 0$ និង $q$ ជាផលចែកពេល $a$ ចែកនឹង $b$ នោះ $q = \left\lfloor \frac{a}{b} \right\rfloor$ ។

ខ) ចំពោះចំនួនពិតវិជ្ជមាន $x$ និងចំនួនគត់ $n$ ។ ចំនួនពហុគុណវិជ្ជមាននៃ $n$ ដែលមិនធំជាង $x$ គឺ $\left\lfloor \frac{x}{n} \right\rfloor$ ។

**១២០** ចូររកចំនួនគត់វិជ្ជមាន $n$ និងមុំស្រួចទាំងបីនៃត្រីកោណ $ABC$ បើគេមានសមភាព

$$\sqrt[2020]{\tan^n A} + \sqrt[2020]{\tan^n B} + \sqrt[2020]{\tan^n C} = \frac{n\left(3\sqrt{3}-1\right)+6060}{2018}$$ ។

ដំណោះស្រាយ

ដោយមុំទាំងបី $A, B, C$ ជាមុំស្រួច នោះ $\tan A > 0, \tan B > 0$ និង $\tan C > 0$

យើងមាន $\begin{cases} \tan A + \tan B + \tan C = \tan A.\tan B.\tan C \\ \tan A + \tan B + \tan C \geq 3\sqrt[3]{\tan A.\tan B.\tan C} \end{cases}$

$$\Rightarrow \tan A.\tan B.\tan C \geq 3\sqrt{3} \qquad (1)$$

តាមវិសមភាពកូស៊ី យើងបាន

$$\sqrt[2020]{\tan^n A} + \sqrt[2020]{\tan^n B} + \sqrt[2020]{\tan^n C} \geq 3\left(\tan A.\tan B.\tan C\right)^{\frac{n}{6060}} \geq 3\left(3\sqrt{3}\right)^{\frac{n}{6060}} \quad (2)$$

តាមវិសមភាព Bernoulli យើងបាន

$$3\left(3\sqrt{3}\right)^{\frac{n}{6060}} = 3\left[1+\left(3\sqrt{3}-1\right)\right]^{\frac{n}{6060}} \geq 3\left[1+\frac{n}{6060}\left(3\sqrt{3}-1\right)\right]$$

$$= \frac{n\left(3\sqrt{3}-1\right)+6060}{2020} \qquad (3)$$

តាម $(2)$ និង $(3)$ យើងបាន

$$\sqrt[2020]{\tan^n A} + \sqrt[2020]{\tan^n B} + \sqrt[2020]{\tan^n C} \geq \frac{n\left(3\sqrt{3}-1\right)+6060}{2018}$$



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

តាម $(1),(2)$ និង $(3)$ សមភាពកើតមាកាលណា $\begin{cases} \dfrac{n}{6060}=1 \\ \tan A=\tan B=\tan C \end{cases}$

$$\Rightarrow \begin{cases} n=6060 \\ A=B=C=\dfrac{\pi}{3} \end{cases}$$

ដូចនេះ $n=6060,\ A=B=C=\dfrac{\pi}{3}$

**ដំណឹងសិក្សា**

យើងខ្ញុំមានក្រុមគ្រូបង្រៀនដែលទទួលបង្រៀនសិស្សដល់ផ្ទះនៅរាជធានីភ្នំពេញគ្រប់មុខវិជ្ជាពីថ្នាក់ទី ៧ដល់ថ្នាក់ទី ១២ ក្នុងតម្លៃសមរម្យ ។ កម្មវិធីបង្រៀនមានដូចជា ត្រៀមប្រលងសញ្ញាបត្របឋមភូមិ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) អាហារូបករណ៍ ត្រៀមប្រលងពេទ្យ ត្រៀមប្រលងគយនិង ត្រៀមប្រលងសិស្សពូកែ ទំនាក់ទំនងសិក្សាតាមរយៈលេខទូរសព្ទ

098 35 92 94 ឬ 092 42 83 25!

## លំហាត់ស្រាវជ្រាវត្រៀមប្រលង

**លំហាត់ទី ០១៖** គេអោយ $a_1^2+a_2^2+\cdots+a_n^2=1$ ។ ស្រាយបញ្ជាក់ថា $\left|\frac{a_1}{2}+\frac{a_2}{3}+\cdots+\frac{a_n}{n+1}\right|<\sqrt{2}$ ។

**លំហាត់ទី ០២៖** បង្ហាញថាចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ,$n^2+2n+12$ មិនមែនជាពហុគុណនៃ 121 ទេ ។

**លំហាត់ទី ០៣៖** ស្រាយបញ្ជាក់ថាសមីការ $x^3+11^3=y^3$ គ្មានចម្លើយជាចំនួនគត់ $x,y$ ទេ។

**លំហាត់ទី ០៤៖** $a,b,c$ are the three sides of triangle $ABC$. $l_A,l_B,l_C$ are the three angle bisectors of $\Delta ABC$. Prove that $\frac{l_A+l_B}{c}+\frac{l_B+l_C}{a}+\frac{l_C+l_A}{b}\le 3\sqrt{3}$.

**លំហាត់ទី ០៥៖** Let $m_a,m_b,m_c$ be the medians of a triangle $ABC$. $R$ is the radius of the circumscribe circle of triangle $ABC$. Prove that $m_a m_b m_c\le\frac{27R^3}{8}$.

**លំហាត់ទី ០៦៖** ចំណុច $M$ និង $N$ នៅលើអ៊ីប៉ូតេនុសនៃត្រីកោណកែង $ABC$ ដែល $BC=BM$ និង $AC=AN$ ។ ស្រាយបញ្ជាក់ថា $\angle MCN=45^0$ ។

**លំហាត់ទី ០៧៖** Find all integers $a,b,c$ for which $(x-a)(x-10)+1=(x+b)(x+c)$ for all $x$.

**លំហាត់ទី ០៨៖** Find the smallest prime factor of $101^{303}+303^{101}$.

**លំហាត់ទី ០៩៖** រកគ្រប់ចំនួនគត់ $x,y,z$ ដែល $x^2+y^2+z^2=2(yz+1)$ និង $x+y+z=4018$ ។

**លំហាត់ទី ១០៖** គេអោយ $ABCDE$ ជាបញ្ចកោណប៉ោងដែលមាន $AB=AE=CD=1$ និង $\angle ABC=\angle DEA=90^0$ ហើយ $BC+DE=1$ ។ ចូរគណនាក្រឡាផ្ទៃបញ្ចកោណ ។

**លំហាត់ទី ១១៖** ចូររកដោយធ្វើសម្រាយបញ្ជាក់គ្រប់ចម្លើយនៃសមីការ $2^n=a!+b!+c!$ ។

**លំហាត់ទី ១២៖** Let $ABC$ be a triangle with sides $BC,CA,AB$ of length $a,b,c$ respectively. Let $D,E$ be the midpoints of the sides $AC,AB$ respectively. Prove that $BD$ is perpendicular to $CE$ if, and only if $b^2+c^2=5a^2$.

**លំហាត់ទី ១៣៖** គេអោយ $x_1,x_2,\cdots,x_n$ និង $y_1,y_2,\cdots,y_n$ ជាចំនួនពិតសេរី( ចំនួនពិតណាមួយក៏បាន ) ដែលផ្ទៀងផ្ទាត់ $x_1^2+x_2^2+\cdots+x_n^2=1$ និង $y_1^2+y_2^2+\cdots+y_n^2=1$ ។



រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក II

បង្ហាញថា $(x_1y_2 - x_2y_1)^2 \le 2\left|1-\sum_{k=1}^{n} x_k y_k\right|$ រួចរកលក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីអោយសមភាពកើតឡើង។

**លំហាត់ទី ១៤៖** រង្វង់ $C_1, C_2, C_3, C_4$ មានអង្កត់ផ្ចិត $AB, AC, CD, DB$ រៀងគ្នា ។ បរិមាត្ររង្វង់ $C_1$ គឺ 2016 ។ គណនាផលបូកបរិមាត្ររង្វង់ទាំងបួន ។




**លំហាត់ទី ១៥៖** $a,b,c$ ជាចំនួនគត់វិជ្ជមានដែលផ្ទៀងផ្ទាត់

$$ab + ac = 144$$
$$ab + bc = 209$$
$$ac + bc = 221$$

រកតម្លៃនៃ $a^2 + b^2 + c^2$ ។

**លំហាត់ទី ១៦៖** នៅក្នុងប្រមាណវិធីខាងក្រោម អក្សរផ្សេងគ្នាតំណាងអោយលេខផ្សេងគ្នា។ តើចំនួនដែលមានប្រាំខ្ទង់ $SIXTY$ ជាលេខអ្វី?

$$\begin{array}{r} FORTY \\ TEN \\ TEN \\ \hline SIXTY \end{array}$$

**លំហាត់ទី ១៧៖** រកចំនួនគត់ដែលនៅក្បែរ $10\sqrt{0.7} + 10\sqrt{2.8}$ បំផុត ។

**លំហាត់ទី ១៨៖** ប្រសិនបើផលបូក និង ផលគុណនៃចំនួនពិតវិជ្ជមានស្មើ 13ដូចគ្នា។ រក ផលបូកការេនៃចំនួនទាំងពីរ ។

**លំហាត់ទី ១៩៖** ចំនួន 123456789101112.... ដោយប្រើចំនួនគត់ធម្មជាតិ $1,2,3,\cdots$ ។ គេសរសេររហូតបានលេខដែលមាន 201ខ្ទង់ ។ចូររកសំណល់ពេលគេចែកវានឹង 9 ។

**លំហាត់ទី ២០៖** $ABCD$ ជាចតុកោណកែងដែលមាន $AB=34$ និង $BC=12$ ។ $P$ និង $Q$ ជាចំណុចនៅលើជ្រុង $AB$ និង $CD$ រៀងគ្នា ដែល $\angle CPQ$ និង $\angle PQA$ ជាមុំកែង។ រកផលបូកនៃប្រវែងពីរដែលអាចកើតមាននៃជ្រុង $AP$ ។




**លំហាត់ទី ២១៖** គេអោយ $x,y,z$ ជាចំនួនគត់ដែលផ្ទៀងផ្ទាត់សមីការ $x^2+y-z=124$ និង $x+y^2-z=100$ ។ រកតម្លៃនៃ $x+y+z$ ។

**លំហាត់ទី ២២៖** $a,b$ ជាចំនួនគត់ហើយ $\sqrt{3-2\sqrt{2}}$ ជាឫសមួយនៃសមីការ $x^2+ax+b=0$ ។ រកតម្លៃនៃ $a-b$ ។

**លំហាត់ទី ២៣៖** រកចំនួនគត់ $n$ តូចបំផុតដែល

$$2n.\left(45-\sqrt{2016}\right)>1$$ ។

**លំហាត់ទី ២៤៖** គេអោយ $x,y,z$ ជាចំនួនពិតដែល $x+y+z=1$ និង $xy+yz+zx=\frac{1}{3}$ ។ រកតម្លៃនៃ $\frac{4x}{y+1}+\frac{16y}{z+1}+\frac{64z}{x+1}$ ។

**លំហាត់ទី ២៥៖** $ABC$ ជាត្រីកោណសមបាតមួយដែលមាន $BA=BC$ និង $\angle ABC=100^0$ ។ បើ $D$ ជាចំណុចមួយនៅលើ $BA$ ត្រូវបានគេសង់យ៉ាងណាឲ្យបាន $BD=AC$ ។ ចូររក $\angle BDC$ ។



**លំហាត់ទី ២៦៖** រកគ្រប់ចំនួនគត់វិជ្ជមាន $n$ ដែលផ្ទៀងផ្ទាត់

$$\frac{1}{n^2+5n+6}+\frac{1}{n^2+7n+12}+\frac{1}{n^2+9n+20}=\frac{1}{270}$$ ។

**លំហាត់ទី ២៧៖** $ABC$ ជាត្រីកោណសមបាតមួយដែលមាន $AB=AC=3$ ។ $k$ ចំណុចផ្សេងគ្នាស្ថិតនៅលើជ្រុង $BC$ តាងដោយ $P_1,P_2,\cdots,P_k$ ។ តាង $x_i=AP_i^2+BP_i.P_iC$ ដែល $i=1,2,3,\cdots,k$ ។ រកតម្លៃនៃ $k$ បើ $x_1+x_2+\cdots+x_k=1080$ ។

**លំហាត់ទី ២៨៖** គេអោយ $n_1,n_2,\cdots,n_9$ ជាប្រាំបួនចំនួនគត់វិជ្ជមានខុសៗគ្នា ដែល $n_1<n_2<\cdots<n_9$ ហើយ $n_1+n_2+\cdots+n_9=180$ ។ ឧបមាថាផលបូក $n_1+n_2+n_3+n_4+n_5$ មានតម្លៃអតិបរមា ។ រកតម្លៃអតិបរមាដែលអាចនៃ $n_9-n_1$ ។

**លំហាត់ទី ២៩៖** ក្នុងរូបខាងក្រោម ការេ $ABCD$ មានក្រឡាផ្ទៃ 512 ។ គេសង់ការេ $A_1B_1C_1D_1$ នៅខាងក្នុងការេ $ABCD$ ដោយយក $AA_1=\frac{1}{4}AB, BB_1=\frac{1}{4}BC$ , $CC_1=\frac{1}{4}CD$ និង $DD_1=\frac{1}{4}AD$ ។ បន្ទាប់មកគេសង់ការេមួយទៀត $A_2B_2C_2D_2$ នៅខាងក្នុងការេ $A_1B_1C_1D_1$ ដោយយក $A_1A_2=\frac{1}{4}A_1B_1, B_1B_2=\frac{1}{4}B_1C_1, C_1C_2=\frac{1}{4}C_1D_1$ និង $D_1D_2=\frac{1}{4}D_1A_1$ ។ គេបន្តការសង់របៀបនេះទៀតបានការេ $A_3B_3C_3D_3$ ។ រកក្រឡាផ្ទៃការេ $A_3B_3C_3D_3$ ។




ចម្លើយលំហាត់ស្រាវជ្រាវមានក្នុងសៀវភៅបន្ត...

# ឯកសារយោង


1. www.google.com
2. Vietnamese mathematical documents
3. Mathematical Olympiad in China
4. Infinity
5. A Gentle Introduction to the American Invitational Mathematics Examination
6. Number Theory ,Titu Andreescu
7. Putnam and Beyond, Titu Andreescu
8. Singapore Mathematical Olympiad




រក្សាសិទ្ធិដោយបណ្ណាគារ បាក់ទូក ॥